ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

(គ.ជ.ប)

# សៀវភៅណែនាំ

ស្ដីពី

# នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

អាណត្តិទី៤ ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

(គ.ជ.ប)

## សៀវភៅណែនាំ

## ស្តីពី

## នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៤ ឆ្នាំ២០២៤

# មាតិកា

**ទំព័រ**

**អក្សរកាត់**------------------------------------------------------------------------------------ i
**គោលបំណង** ------------------------------------------------------------------------------- ii
**ជំពូកទី ១ នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង**----------១
**ផ្នែកទី ១ ការប្តឹងតវ៉ា ឬការប្តឹងជំទាស់**-----------------------------------------១
១. ពាក្យបណ្តឹង-----------------------------------------------------------------------១
២. ការរាប់ចំនួនថ្ងៃតវ៉ា ឬថ្ងៃជំទាស់ និងការសម្រេចលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់------------------------------------------------------------ ២
**ផ្នែកទី២ នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងទាក់ទងនឹងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ** ---------------------------------------------- ៣
១. ភាពមានសិទ្ធិឈរឈ្មោះជាបេក្ខជន ----------------------------------------៣
២. ភាពគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជន ----------------------------------------៤
៣. ការដាក់ពាក្យសុំច្បាប់ឈប់ពិសេស -----------------------------------------៤
៤. ការដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ-----------------------------------------------------៥
៥. ការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ----------------------------------------------- ៧
៦. ការពិនិត្យសម្រេចរបស់ គធ.ខប --------------------------------------------៨
៧. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប --------៩
៧.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គ.ជ.ប -------------------៩
៧.២ ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ----------------------------៩
**ផ្នែកទី៣ នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង** ------------------------------------ ១២
១. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប ----១៣
១.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គធ.ខប -------------------១៣
១.២ ការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប --------------------------- ១៥

២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ----- ១៦
២.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គ.ជ.ប -------------------- ១៦
២.២ ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ---------------------------- ១៨
**ផ្នែកទី ៤ ការអនុវត្តសេចក្តីសម្រេចស្ថាពររបស់ គឃ.ខប ឬសេចក្តីសម្រេចស្ថាពររបស់ គ.ជ.ប ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង** -----------២២
**ផ្នែកទី ៥ នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី៣ ថ្មី (អំពីទោសប្បញ្ញត្តិ) នៃ ច.ប.ក** ------------------------------------- ២៣
I. ពាក្យបណ្តឹងពាក់ព័ន្ធនឹងជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ------------------------------------------------------------------២៣
១. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គឃ.ខប ----២៣
១.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គឃ.ខប -------------------២៣
១.២ ការដោះស្រាយពាក្យបណ្តឹងនៅ គឃ.ខប --------------------------- ២៥
២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ----- ២៨
២.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គ.ជ.ប-------------------- ២៨
២.២ ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ---------------------------- ២៩
II. ពាក្យបណ្តឹងពាក់ព័ន្ធនឹងជនដែលជាមន្ត្រីបោះឆ្នោត------------------ ៣៣
**ផ្នែកទី ៦ នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងទាក់ទងនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងភាពមិនប្រក្រតីនៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោតព្រមទាំងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត** -------------៣៥
១. ការតវ៉ា ឬការជំទាស់ និងការដោះស្រាយនៅ គ.ក.ប/គ.ក.រ -------៣៥
១.១ ការតវ៉ា ឬការជំទាស់នៅ គ.ក.ប/គ.ក.រ ------------------------------------៣៥
១.២ ការដោះស្រាយចំពោះការតវ៉ា ឬការជំទាស់នៅ គ.ក.ប/គ.ក.រ-------៣៥
២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គឃ.ខប --- ៣៧
២.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គឃ.ខប----------------------- ៣៧
២.២ ការដោះស្រាយពាក្យបណ្តឹងនៅ គឃ.ខប---------------------------------៤០

៣.ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ------ ៤២
៣.១ ការដាក់ ការទទួលពាក្យបណ្តឹងនៅ គ.ជ.ប --------------------------- ៤២
៣.២ ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប------------------------------------៤៥
៣.៣ ការត្រួតពិនិត្យលទ្ធផលដែល គជ.ឃប បានសម្រេចព្យួរជា បណ្តោះអាសន្ន ----------------------------------------------------------------៤៨
**ផ្នែកទី ៧ នីតិវិធីអនុវត្តសេចក្តីសម្រេចស្តាពរចំពោះការដាក់ទណ្ឌកម្ម ពិន័យជាប្រាក់** --------------------------------------------------------- ៥២
**ជំពូកទី ២ សមត្ថកិច្ចដោះស្រាយវិវាទក្នុងការបោះឆ្នោត**------------------------៥៣
**ផ្នែកទី ១ សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬ ក្រុមប្រឹក្សាជំនុំជម្រះ**---------------------------------------------------------៥៣
១. សមាសភាពរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ ----៥៣
១.១ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គជ.ឃប -------៥៣
១.២ ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ---------------------------------------- ៥៤
២. សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ----- ៥៥
២.១ សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គជ.ឃប ------------------------------------------------------------------- ៥៥
២.២ សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប----------------- ៥៥
**ផ្នែកទី ២ សិទ្ធិ និងកាតព្វកិច្ចរបស់ដើមបណ្តឹង ចុងចម្លើយ មេធាវី ឬតំណាង និងសាក្សី**------------------------------------------------------------- ៥៦
១. សិទ្ធិ និងកាតព្វកិច្ចរបស់គូភាគី ------------------------------------------- ៥៦
២. សិទ្ធិ និងកាតព្វកិច្ចរបស់ដើមបណ្តឹង----------------------------------------- ៥៦
៣. សិទ្ធិ និងកាតព្វកិច្ចរបស់ចុងចម្លើយ--------------------------------------៥៧
៤. សិទ្ធិ និងកាតព្វកិច្ចរបស់មេធាវី ឬតំណាង ----------------------------- ៥៨
៥. សិទ្ធិ និងកាតព្វកិច្ចរបស់សាក្សី ------------------------------------------- ៥៨
**ផ្នែកទី ៣ នីតិវិធីប្រជុំផ្សះផ្សា ឬសវនាការ**---------------------------------- ៥៩
១. ប្រភេទសវនាការ -------------------------------------------------------------- ៥៩
២. ភាសាដែលប្រើក្នុងការប្រជុំផ្សះផ្សា ឬសវនាការ------------------------- ៦៩

៣. ពេលវេលាដោះស្រាយពាក្យបណ្ដឹង ---------------------------------------- ៦០
៤. ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកសវនាការ ------------------ ៦០
៤.១ ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា នៅ គធ.ខប ------------------ ៦០
៤.២ ការជូនដំណឹងបើកសវនាការនៅ គ.ជ.ប --------------------------- ៦០
៥. ភារកិច្ចរបស់លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការសវនាការ ឬ
គណៈលេខាធិការសវនាការ ------------------------------------------ ៦១
៦. ការរៀបចំកន្លែង និងរបៀបរបបការងាររបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬ
ឬក្រុមប្រឹក្សាជំនុំជម្រះ ------------------------------------------------ ៦២
៧. ការបង្ហាញខ្លួននៅពេលប្រជុំផ្សះផ្សា ឬសវនាការ ---------------------៦៣
៨. មធ្យោបាយបង្ហាញភស្តុតាង --------------------------------------------- ៦៤
៩. ការបំពេញ និងប្រើប្រាស់សម្រង់សេចក្ដីសម្រេច (ទ.១២០៣) -------- ៦៥
១០. ទម្រង់បែបបទផ្សេងៗទៀតសម្រាប់ការប្រជុំផ្សះផ្សា ឬសវនាការ -- ៦៦
**ឧបសម្ព័ន្ធ** ------------------------------------------------------------------ ៦៨
**ឧបសម្ព័ន្ធទី ១ ទម្រង់បែបបទពាក្យបណ្ដឹង** (**ទ.១២០២**) -------------------៦៨
**ឧបសម្ព័ន្ធទី ២ ទម្រង់បែបបទសម្រង់សេចក្ដីសម្រេច** (**ទ.១២០៣**) ------៦៩
**ឧបសម្ព័ន្ធទី ៣ បទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬសវនាការ
ដោះស្រាយពាក្យបណ្ដឹង** -------------------------------------- ៧០
**ឧបសម្ព័ន្ធទី ៤ នីតិវិធី និងខ្លឹមសារនៃសម្បថ** ------------------------------ ៧១

# អក្សរកាត់

| | |
|---|---|
| - គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | គ.ជ.ប |
| - គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | គធ.ខប |
| - លេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | លគធ.ខប |
| - ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ | ក្រុមប្រឹក្សា |
| - ក្រុមប្រឹក្សាឃុំ សង្កាត់ | កបឃ.ស |
| - គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត | គ.ក.ប/គ.ក.រ |
| - ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | ច.គ.ជ.ប |
| - ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ | ច.ប.ត.រ |
| - ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ | ច.ប.ក |
| - ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់បោះឆ្នោត | ច.វ.ច.ប |
| - បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ | ប.ន.ក |
| - នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត | ន.គ.ទ.ប |
| - អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | អ.ខ |
| - ទម្រង់បែបបទលេខ | ទ. |
| - ទម្រង់បែបបទពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ | ទ.១០០៨ |
| - ទម្រង់បែបបទពាក្យបណ្តឹង | ទ.១២០២ |
| - ទម្រង់បែបបទសម្រេចសេចក្តីសម្រេច | ទ.១២០៣ |

# គោលបំណង

សៀវភៅណែនាំស្ដីពី**នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៤ ឆ្នាំ២០២៤** ត្រូវបានរៀបចំឡើង ដោយផ្អែកលើ ច.គ.ជ.ប ច.ប.ក ច.ប.ត.រ ច.វ.ច.ប និង ប.ន.ក ។

សៀវភៅណែនាំនេះ រៀបចំឡើងដើម្បីជាជំនួយស្មារតីសម្រាប់មន្ត្រីបោះឆ្នោត និងភាគីពាក់ព័ន្ធទាំងអស់ឱ្យបានយល់ដឹងអំពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាអាណត្តិទី៤ ឆ្នាំ២០២៤។ សៀវភៅណែនាំនេះចែកចេញជាពីរជំពូក ៖

**ជំពូកទី ១** បង្ហាញដោយសង្ខេបអំពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង នៅគ្រប់ដំណាក់កាលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាអាណត្តិទី៤ ឆ្នាំ២០២៤។

**ជំពូកទី ២** បង្ហាញដោយសង្ខេបអំពីសមត្ថកិច្ច និងនីតិវិធីប្រជុំផ្សះផ្សា ឬសវនាការដោះស្រាយពាក្យបណ្ដឹងដែលកើតមានឡើងនៅគ្រប់ដំណាក់កាលក្នុងនោះមានជាអាទិ៍ សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សាឬក្រុមប្រឹក្សាជំនុំជម្រះប្រភេទសវនាការសិទ្ធ និងកាតព្វកិច្ចរបស់ភាគីពាក់ព័ន្ធនឹងពាក្យបណ្ដឹង។

ផ្នែកខាងក្រោមនៃសៀវភៅណែនាំនេះមាន ៤ (បួន) ឧបសម្ព័ន្ធ ៖

- ឧបសម្ព័ន្ធទី១ ទម្រង់បែបបទពាក្យបណ្ដឹង (ទ.១២០២)
- ឧបសម្ព័ន្ធទី២ ទម្រង់បែបបទសម្រង់សេចក្ដីសម្រេច (ទ.១២០៣)
- ឧបសម្ព័ន្ធទី៣ បទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬសវនាការដោះស្រាយពាក្យបណ្ដឹង
- ឧបសម្ព័ន្ធទី៤ នីតិវិធី និងខ្លឹមសារនៃសម្បថ។

# ជំពូកទី១
# នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង
## ផ្នែកទី១
## ការប្ដឹងតវ៉ា ឬការប្ដឹងជំទាស់

ជនណាក៏ដោយ ឬតំណាងមានសិទ្ធិប្ដឹងតវ៉ា ឬ/និងប្ដឹងជំទាស់តាមឋានានុក្រមទៅ គធ.ខប ឬ គ.ជ.ប អំពីបញ្ហាទាំងឡាយដែលទាក់ទងនឹងការបោះឆ្នោត ប្រសិនបើមានភស្តុតាងបញ្ជាក់ថា មានភាពមិនត្រឹមត្រូវតាមបទប្បញ្ញត្តិនៃ ច.ប.ក ឬ/និង ច.ប.ត.រ ឬ/និង ច.វ.ច.ប ឬ/និង ប.ន.ក ឬ/និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប លើកលែងតែការប្ដឹងតវ៉ា និងការប្ដឹងជំទាស់ទាក់ទងនឹងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ដែលត្រូវប្ដឹងដោយសាមីគណបក្សនយោបាយ ឬសាមីបេក្ខជន និងការប្ដឹងទាក់ទងនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ដែលត្រូវប្ដឹងដោយមន្ត្រីការិយាល័យបោះឆ្នោត ឬភ្នាក់ងារគណបក្សនយោបាយ ព្រមទាំងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ដែលត្រូវប្ដឹងដោយជនដែលមានសិទ្ធិបោះឆ្នោតក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬតំណាងគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះ។

### ១. ពាក្យបណ្ដឹង

ពាក្យបណ្ដឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរតាម ទ.១២០២ ចំនួន ៣ (បី) ច្បាប់ (**ករណីប្ដឹងតវ៉ា**) ឬចំនួន ៤ (បួន) ច្បាប់ (**ករណីប្ដឹងជំទាស់**)។ ទ.១២០២ នេះ ត្រូវបានប្រគល់ជូនអ្នកប្ដឹងដើម្បីប្ដឹង ឬប្ដឹងបន្តប្រសិនបើមានការស្នើសុំ។

អ្នកប្ដឹងដំបូងអាចថតចម្លង ទ.១២០២ ដែលខ្លួនបានបំពេញ រួចចុះហត្ថលេខា ឬផ្ដិតមេដៃលើច្បាប់ចម្លងនោះដោយខ្លួនឯង ហើយអាចដាក់ពាក្យបណ្ដឹងដោយផ្ទាល់ ឬអាចប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យតំណាងដាក់ពាក្យបណ្ដឹងជួសខ្លួនបាន។

ពាក្យបណ្ដឹងត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួន ដូចខាងក្រោម ៖

១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬតំណាង។
២- កម្មវត្ថុនៃពាក្យបណ្ដឹង។
៣- ប្រភេទនៃអំពើល្មើស។
៤- ពេលវេលា និងទីកន្លែងនៃការប្រព្រឹត្តអំពើល្មើស ឬភាពមិនប្រក្រតីកើតឡើង។
៥- បើអាចធ្វើបានបញ្ជាក់អំពីមាត្រាច្បាប់បោះឆ្នោតដែលត្រូវបានរំលោភ។
៦- អត្តសញ្ញាណរបស់ជនដែលពាក់ព័ន្ធនឹងការប្ដឹងតវ៉ា ឬការប្ដឹងជំទាស់។
៧- ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី (ប្រសិនបើមាន)។
៨- ភស្តុតាងផ្សេងៗទៀត (ប្រសិនបើមាន)។

ពាក្យបណ្ដឹងអនាមិក ពុំត្រូវបានចាត់ទុកជាពាក្យបណ្ដឹងស្របច្បាប់ និងមិនត្រូវលើកយកមកដោះស្រាយ ប៉ុន្តែត្រូវបានចាត់ទុកជាឯកសារព័ត៌មានសម្រាប់ការពិចារណា។

ពាក្យបណ្ដឹងប្ដឹងពីអញ្ញាតជន[១] ត្រូវបានចាត់ទុកជាពាក្យបណ្ដឹងស្របច្បាប់ និងត្រូវបានសហការជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត ដើម្បីស្វែងរកអត្តសញ្ញាណរបស់អ្នកប្រព្រឹត្តល្មើសនោះ និងពង្រឹងការការពារ និងទប់ស្កាត់បន្ថែម។ ក្នុងករណីដែលស្វែងរកអត្តសញ្ញាណអញ្ញាតជនមិនឃើញ គធ.ខប ឬ គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងទៅអ្នកប្ដឹងវិញអំពីករណីនេះក្នុងរយៈពេលសមស្រប។

## ២. ការរាប់ចំនួនថ្ងៃតវ៉ា ឬថ្ងៃជំទាស់ និងការសម្រេចលើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់

ថ្ងៃធ្វើការកំណត់ទាំងថ្ងៃសៅរ៍ ទាំងថ្ងៃអាទិត្យ ប៉ុន្តែការរាប់ចំនួនថ្ងៃតវ៉ា ឬថ្ងៃជំទាស់ និងការសម្រេចលើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ពុំត្រូវបានរាប់បញ្ចូលថ្ងៃបុណ្យជាផ្លូវការ ដែលកំណត់ក្នុងអនុក្រឹត្យស្ដីពីប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិក កម្មករប្រចាំឆ្នាំ។

[១] ជនមិនស្គាល់អត្តសញ្ញាណ

## ផ្នែកទី២
## នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង ទាក់ទងនឹងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ

### ១. ភាពមានសិទ្ធិឈរឈ្មោះជាបេក្ខជន

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបំពេញលក្ខខណ្ឌ និងមានលក្ខណសម្បត្តិដូចខាងក្រោម៖

១.១ មានសញ្ជាតិខ្មែរពីកំណើត។

១.២ មានអាយុយ៉ាងតិច ២៥ (ម្ភៃប្រាំ) ឆ្នាំ គិតដល់ថ្ងៃបោះឆ្នោត។

១.៣ មានសិទ្ធិបោះឆ្នោត និងមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមលក្ខខណ្ឌដែលកំណត់ដោយ ច.ប.ក ។

១.៤ បានអនុវត្តសិទ្ធិបោះឆ្នោតដោយបានបោះឆ្នោតសម្រាប់ការបោះឆ្នោតជាសកលលើកចុងក្រោយ ដែលរៀបចំឡើងដោយ គ.ជ.ប លើកលែងតែករណីដែលមិនអាចអនុវត្តសិទ្ធិបោះឆ្នោតនេះ មានមូលហេតុសមស្រប។

មូលហេតុសមស្របនៃការមិនអាចអនុវត្តសិទ្ធិបោះឆ្នោតពាក់ព័ន្ធនឹងលក្ខខណ្ឌដើម្បីមានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាដូចមានចែងក្នុងចំណុច ១.៤ ខាងលើ ត្រូវបានកំណត់ដូចខាងក្រោម ៖

- ស្ថិតនៅក្រៅប្រទេស នៅថ្ងៃបោះឆ្នោត ដោយសារជាប់បំពេញបេសកកម្មផ្លូវការ ឬបំពេញការសិក្សា ឬបំពេញការងារដែលមានកិច្ចសន្យាការងារស្របច្បាប់
- មានជំងឺដែលមិនអាចទៅបោះឆ្នោតបាន នៅថ្ងៃបោះឆ្នោត
- ស្ត្រីសម្រាលកូន នៅថ្ងៃបោះឆ្នោត
- ត្រូវបានព្យួរសិទ្ធិបោះឆ្នោតជាបណ្តោះអាសន្នស្របតាមច្បាប់ជាធរមាន
- ករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ដែលអ្នកបោះឆ្នោតមិនអាចបោះឆ្នោតបានស្របតាមបទប្បញ្ញត្តិនៃបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត។

អ្នកបោះឆ្នោតដែលមិនបានអនុវត្តសិទ្ធិបោះឆ្នោត ដោយមូលហេតុសមស្របដូចមានចែងក្នុងកថាខណ្ឌទី២ ខាងលើ ហើយមានបំណងឈរឈ្មោះបោះឆ្នោតត្រូវបញ្ជាក់ពីមូលហេតុ និងត្រូវមានឯកសារសំអាងត្រឹមត្រូវ និងច្បាស់លាស់ដល់ គ.ជ.ប ។

## ២. ភាពគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជន

គ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ចំពោះ ៖

២.១ សមាជិករដ្ឋសភា ព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ រាជរដ្ឋាភិបាល និងចៅក្រម។

២.២ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

២.៣ អភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

២.៤ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។

២.៥ សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការរៀបចំការបោះឆ្នោត និងមន្ត្រី បុគ្គលិកបម្រើការងាររៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។

២.៦ មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ នគរបាលជាតិក្នុងមុខតំណែង។

២.៧ មន្ត្រី បុគ្គលិករបស់ក្រុមប្រឹក្សាគ្រប់លំដាប់ថ្នាក់។

២.៨ ជនដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ។

២.៩ ជនវិកលចរិត ឬជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ដែលមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច។

២.១០ ជនដែលត្រូវបានដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬជនដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដោយ គ.ជ.ប ។

២.១១ ព្រះសង្ឃ ឬបព្វជិតសាសនា។

## ៣. ការដាក់ពាក្យសុំច្បាប់ឈប់ពិសេស

មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ នគរបាលជាតិ កងយោពលខេមរភូមិន្ទ មន្ត្រី បុគ្គលិករបស់ក្រុមប្រឹក្សាគ្រប់លំដាប់ថ្នាក់ ដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេសយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃមុនថ្ងៃបើកការឃោសនាបោះឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ។

លិខិតបញ្ជាក់ការអនុញ្ញាតច្បាប់ឈប់ពិសេសពីក្រសួង ស្ថាប័ន ឬអង្គភាព អាចភ្ជាប់មកជាមួយពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និង បញ្ជីបេក្ខជនឈរឈ្មោះ។ ក្នុងករណីមិនអាចធ្វើទាន់ គណបក្សនយោបាយត្រូវភ្ជាប់ ច្បាប់ថតចម្លងលិខិតស្នើសុំអនុញ្ញាតច្បាប់ឈប់ពិសេសពីក្រសួង ស្ថាប័ន ឬអង្គភាព ដោយមានចុះហត្ថលេខារបស់ថ្នាក់លើមួយថ្នាក់យ៉ាងតិចដែលខ្លួននៅក្រោមឱវាទជូន គធ.ខប ។ បេក្ខជនឈរឈ្មោះត្រូវធ្វើកិច្ចសន្យាតាមទម្រង់ដែលផ្តល់ជូនដោយ គ.ជ.ប ដើម្បីធានាថានឹងប្រគល់លិខិតអនុញ្ញាតច្បាប់ឈប់ពិសេស ដែលប្រធានក្រសួង ស្ថាប័ន ឬអង្គភាពសម្រេចជាផ្លូវការមក គធ.ខប ឱ្យបានយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃចាប់ផ្តើមបើកការឃោសនាបោះឆ្នោត។

## ៤. ការដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និង បញ្ជីបេក្ខជនឈរឈ្មោះ

**ក.** គណបក្សនយោបាយ ដែលបានចុះបញ្ជីស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ ហើយមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និង បញ្ជីបេក្ខជនឈរឈ្មោះ (ទ.១០០៨) ទៅ គធ.ខប ។ ទ.១០០៨ នេះ ត្រូវបាន ផ្តល់ជូនដោយឥតគិតថ្លៃ។

**ខ.** គណបក្សនយោបាយត្រូវបំពេញ ទ.១០០៨ ចំនួន ២ (ពីរ) ច្បាប់ ហើយត្រូវ ចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយ ឬតំណាងដែលបានទទួល ការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយនោះ។ ការផ្ទេរសិទ្ធិនេះ មិនអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្តឡើយ លើកលែងតែក្នុង លិខិតផ្ទេរសិទ្ធិនោះ មានខ្លឹមសារអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្ត។

**គ.** គណបក្សនយោបាយត្រូវរៀបចំបញ្ជីបេក្ខជនរបស់ខ្លួន តាមមណ្ឌល បោះឆ្នោត និងតាមប្រភេទក្រុមប្រឹក្សានីមួយៗ ហើយត្រូវបំពេញបែបបទ សេចក្តីប្រកាសបេក្ខភាពដែលផ្តល់ដោយ គ.ជ.ប តាមរយៈ គធ.ខប ។ បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតតាមមណ្ឌលបោះឆ្នោត និងតាមប្រភេទ ក្រុមប្រឹក្សានីមួយៗ ត្រូវ ៖

**១-** បញ្ជាក់ច្បាស់ពីប្រភេទក្រុមប្រឹក្សា ដែលបញ្ជីបេក្ខជនត្រូវឈរឈ្មោះ បោះឆ្នោត។

២- រៀបចំឈ្មោះតាមលំដាប់អាទិភាពពីខ្ពស់មកទាប តាមការកំណត់របស់គណបក្សនយោបាយ និងត្រូវធានាឱ្យមានបេក្ខជនស្ត្រីចូលរួម និងមានឈ្មោះនៅលំដាប់លេខរៀងសមស្របក្នុងបញ្ជីបេក្ខជននោះ។

៣- បញ្ជីបេក្ខជននៃគណបក្សនយោបាយ ត្រូវមានបេក្ខជនពេញសិទ្ធិ និងបេក្ខជនបម្រុង ដែលមានចំនួនបេក្ខជនយ៉ាងតិច ២ (ពីរ) ដង នៃចំនួនអាសនៈសម្រាប់ក្រុមប្រឹក្សាណាមួយ ដែលគណបក្សនយោបាយនោះមានបំណងចូលរួមប្រកួតប្រជែង។

៤- បេក្ខជនម្នាក់ ត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយ និងមានសិទ្ធិឈរឈ្មោះជាបេក្ខជនសម្រាប់ក្រុមប្រឹក្សាតែមួយប៉ុណ្ណោះ។

៥- បេក្ខជនដែលមានឈ្មោះក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយលើសពីមួយ ឬឈរឈ្មោះជាបេក្ខជនសម្រាប់ក្រុមប្រឹក្សាលើសពីមួយ ត្រូវបានប្រកាសថា បាត់សិទ្ធិឈរឈ្មោះជាបេក្ខជនដោយ គ.ជ.ប ។

**ឃ.** ទ.១០០៨ ត្រូវធ្វើជា ២ (ពីរ) ច្បាប់ ដោយភ្ជាប់មកជាមួយនូវ ៖

១- សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ជាសេចក្តីចម្លងប្រកាសស្តីពីការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ដែលមានបញ្ជាក់នីត្យានុកូលកម្មដោយអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ឬការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ១(មួយ) ច្បាប់។ គណបក្សនយោបាយត្រូវផ្ញើសេចក្តីចម្លងប្រកាសនេះ ១ (មួយ) ច្បាប់ មក គ.ជ.ប ដើម្បីតម្កល់ទុក ហើយសម្រាប់ការដាក់ពាក្យសុំចុះបញ្ជីនៅ គធ.ខប គណបក្សនយោបាយគ្រាន់តែថតចម្លងសេចក្តីចម្លងប្រកាសស្តីពីការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃដែលមានបញ្ជាក់នីត្យានុកូលកម្មនេះ ភ្ជាប់ជាមួយ ទ.១០០៨ ។

២- ឈ្មោះគណបក្សនយោបាយជាអក្សរពេញ ជាអក្សរកាត់ និងសញ្ញាសម្គាល់គណបក្សនយោបាយ។

៣- អាសយដ្ឋាននៃទីស្នាក់ការកណ្តាលគណបក្សនយោបាយ និងអាសយដ្ឋានទីស្នាក់ការរបស់គណបក្សនយោបាយ នៅតាមរាជធានី ឬខេត្ត ឬក្រុង ឬស្រុក ឬខណ្ឌ។

៤- បញ្ជីរាយនាមបេក្ខជនឈរឈ្មោះបោះឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗ។ បញ្ជីនេះត្រូវមានចំនួនបេក្ខជនពេញសិទ្ធិ និងបម្រុងដែលមានចំនួនបេក្ខជនយ៉ាងតិច ២ (ពីរ) ដង នៃចំនួនអាសនៈក្រុមប្រឹក្សាណាមួយ ដែលគណបក្សនយោបាយនោះមានបំណងចូលរួមប្រកួតប្រជែង។

៥- សេចក្តីបញ្ជាក់ពីអាជ្ញាធរឃុំ សង្កាត់ អំពីការមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ដែលសាមីបេក្ខជននោះបានចុះឈ្មោះបោះឆ្នោត។

៦- សេចក្តីប្រកាសរបស់គណបក្សនយោបាយថា ចូលរួមបោះឆ្នោត និងទទួលយកលទ្ធផលបោះឆ្នោត ដែលប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ និងចូលរួមអនុវត្ត ច.ប.ក ច.ប.ត.រ ច.វ.ច.ប ច្បាប់ស្តីពីគណបក្សនយោបាយ ប.ន.ក និងក្រមសីលធម៌របស់ គ.ជ.ប ។

៧- សេចក្តីប្រកាសរបស់បេក្ខជន យល់ព្រមឱ្យគណបក្សនយោបាយតែងតាំងខ្លួនជាបេក្ខជន ដើម្បីឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។

## ៥. ការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ

**ក.** ការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត មានរយៈពេល ៥ (ប្រាំ) ថ្ងៃ គឺរៀងរាល់ថ្ងៃ ពេលព្រឹកចាប់ពីម៉ោង ៧:០០ (ប្រាំពីរ) ដល់ ១១:៣០ (ដប់មួយ សាមសិប) នាទី និងពេលរសៀលចាប់ពីម៉ោង ១៤:០០ (ដប់បួន) ដល់ ១៧:៣០ (ដប់ប្រាំពីរ សាមសិប) នាទី។

**ខ.** គធ.ខប ត្រូវចេញបង្កាន់ដៃបញ្ជាក់ការទទួលពាក្យជូនគណបក្សនយោបាយដែលបានដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងរក្សាគល់បញ្ជី ១ (មួយ) ច្បាប់ ទុកជាឯកសារ។

**គ.** បង្កាន់ដៃទទួលពាក្យត្រូវបញ្ជាក់អំពីចំនួន និងប្រភេទឯកសារដែលបានទទួលដោយត្រូវចុះកាលបរិច្ឆេទនៃការប្រគល់ ទទួល និងចុះហត្ថលេខា ឬស្នាមមេដៃរបស់អ្នកប្រគល់ ទទួល។ បន្ទាប់មកមន្ត្រីផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវបញ្ចូលព័ត៌មានរបស់គណបក្សនយោបាយ និងស្កេនបង្កាន់ដៃទទួលពាក្យនោះបញ្ចូលទៅក្នុងកម្មវិធីគ្រប់គ្រងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ។

ឃ. នៅពេលបញ្ចប់ការទទួលពាក្យ គធ.ខប ត្រូវធ្វើកំណត់ហេតុស្តីពីលទ្ធផលនៃការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្នុងរាជធានី ខេត្តរបស់ខ្លួនចំនួន ៣ (បី) ច្បាប់ ដោយមានចុះកាលបរិច្ឆេទ ហត្ថលេខា និងបោះត្រាគធ.ខបរួចបិទផ្សាយ ១ (មួយ) ច្បាប់ នៅ លគធ.ខប ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។ តំណាងគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខាលើកំណត់ហេតុនេះបាន។

ង. បញ្ជីបេក្ខជននៃគណបក្សនយោបាយណា ដែលត្រូវបានដាក់ពាក្យសុំចុះបញ្ជីនៅ គធ.ខប រួចហើយ មិនអនុញ្ញាតឱ្យបេក្ខជនលាឈប់ ឬប្តូរបេក្ខជន ឬដកបញ្ជីបេក្ខជនឈរឈ្មោះឡើយ។ បេក្ខជនអាចលាឈប់ពីបញ្ជីបេក្ខជនឈរឈ្មោះបានបន្ទាប់ពី គធ.ខប ទទួលស្គាល់ផ្លូវការនូវការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ។

## ៦. ការពិនិត្យ និងសម្រេចរបស់ គធ.ខប

ក. គធ.ខប ត្រូវពិនិត្យ សម្រេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យសុំ។

ខ. ក្នុងករណី គធ.ខប យល់ព្រមចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត គធ.ខប ត្រូវចេញលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតរួចផ្ញើជូនសាមីគណបក្សនយោបាយ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

គ. ក្នុងករណី គធ.ខប ពិនិត្យឃើញថា សំណុំឯកសាររបស់គណបក្សនយោបាយណាមួយពុំបានបំពេញលក្ខខណ្ឌដូចមានចែងក្នុង**ចំណុច ១ ដល់ចំណុច ៤ (ទំព័រ៣ ដល់ទំព័រ៥)** គធ.ខប ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅសាមីគណបក្សនយោបាយនោះវិញដើម្បីបំពេញបន្ថែម ឬកែតម្រូវចំណុចដែលខ្វះខាតយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងនេះ។

ឃ. ក្នុងករណី គណបក្សនយោបាយដែលបានទទួលលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរពី គធ.ខប ឱ្យធ្វើការកែតម្រូវចំណុចខ្វះខាតបានកែតម្រូវត្រឹមត្រូវ និងទាន់ពេលវេលាហើយនោះ គធ.ខប ត្រូវយល់ព្រមលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងរយៈពេល ១ (មួយ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យស្នើសុំដែលបានកែតម្រូវរួចហើយ។

ង. ក្នុងករណី គណបក្សនយោបាយណាមួយពុំបានបំពេញលក្ខខណ្ឌ ឬកែតម្រូវចំណុចខ្វះខាតក្នុងរយៈពេលកំណត់ គធ.ខប ត្រូវសម្រេចបដិសេធពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនោះ ដោយត្រូវ ៖

១- ចុះហត្ថលេខា និងកាលបរិច្ឆេទលើសេចក្ដីសម្រេចបដិសេធបេក្ខភាព ឬបញ្ជីរាយនាមបេក្ខជនចំនួន ៣ (បី) ច្បាប់ ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការបដិសេធ រួចត្រូវ ៖
- ប្រគល់ជូនគណបក្សនយោបាយសាមី ឬតំណាង ឬសាមីខ្លួន ១ (មួយ) ច្បាប់
- ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

២- ផ្ដល់ព័ត៌មានទៅសាមីគណបក្សនយោបាយ ឬតំណាង ឬសាមីខ្លួនថា គាត់អាចប្ដឹងតវ៉ាទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្ដីសម្រេចបដិសេធ។

៣- ផ្ដល់ពាក្យបណ្ដឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ ជូនគណបក្សនយោបាយ ឬតំណាង ឬសាមីខ្លួន ដែលត្រូវបានបដិសេធសម្រាប់ប្ដឹងតវ៉ាទៅ គ.ជ.ប (ប្រសិនបើមានការស្នើសុំ)។

# ៧. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប

## ៧.១ ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គ.ជ.ប

ក. គណបក្សនយោបាយ ដែលបានដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ឬបេក្ខភាព ឬបញ្ជីបេក្ខជនរបស់គណបក្សនយោបាយណាមួយដែលត្រូវបានបដិសេធដោយ គធ.ខប សាមីគណបក្សនយោបាយ ឬសាមីខ្លួន ឬតំណាង អាចប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្ដីសម្រេចបដិសេធរបស់ គធ.ខប ។

ខ. អ្នកប្ដឹងត្រូវបំពេញ ទ.១២០២ ចំនួន ៣ (បី) ច្បាប់។

## ៧.២ ការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប

ក. គ.ជ.ប ត្រូវបើកសវនាការសម្រេចលើពាក្យបណ្ដឹងក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង។

**ខ.** ក្នុងករណី គ.ជ.ប សម្រេចបើកសវនាការបដិសេធ ឬយល់ព្រមលើពាក្យបណ្ដឹងតវ៉ា ប្រធានក្រុមប្រឹក្សាជំនុំជំម្រះនៃ គ.ជ.ប ត្រូវចាត់គណៈ-លេខាធិការសវនាការឱ្យស្រង់សេចក្ដីសម្រេច ចូលក្នុងសម្រង់សេចក្ដីសម្រេច (ទ.១២០៣) ចំនួន ៣ (បី) ច្បាប់។ ទ.១២០៣ ត្រូវចុះហត្ថលេខាដោយប្រធានគណៈលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយបោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូន ឬផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**គ.** បន្ទាប់ពីបានទទួលសម្រង់សេចក្ដីសម្រេចយល់ព្រមពី គ.ជ.ប គធ.ខប ត្រូវផ្ដល់ការយល់ព្រមលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនោះ ឬ/និងទទួលយល់ព្រមបេក្ខភាព រួចហើយត្រូវចេញលិខិតបញ្ជាក់អំពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ឬ/និងទទួលយល់ព្រមបេក្ខភាព ឬ/និងបញ្ជីបេក្ខជននៃគណបក្សនយោបាយនោះ រួចប្រគល់ជូនសាមីគណបក្សនយោបាយ ឬសាមីខ្លួន ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ឃ.** សេចក្ដីសម្រេចរបស់ គ.ជ.ប ជាសេចក្ដីសម្រេចចុងក្រោយបិទផ្លូវតវ៉ា។

**ង.** សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវអនុវត្តតាមលក្ខខណ្ឌ**ដូចមានចែងក្នុងជំពូកទី២ ផ្នែកទី១ នៃសៀវភៅណែនាំនេះ (ទំព័រ៥៤ ដល់ទំព័រ៥៥)**។

## ៨. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងទាក់ទង នឹងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ



## ផ្នែកទី៣
## នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង

ជនណាក៏ដោយ ឬតំណាងមានសិទ្ធិប្ដឹងតវ៉ា ឬ/និងប្ដឹងជំទាស់ជាលាយលក្ខណ៍អក្សរតាម ទ.១២០២ ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូងទៅ គឃ.ខប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។

**ពាក្យបណ្ដឹងតវ៉ា** អាចធ្វើឡើងអំពីការបាត់ឈ្មោះ ឬមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែកត់ត្រាមិនច្បាស់លាស់ទៅតាមករណីដូចខាងក្រោម៖

- សាមីអ្នកប្ដឹងតវ៉ាជាសមាជិក កបឃ.ស នៅក្នុងមុខតំណែង ប៉ុន្តែបែរជាមិនមានឈ្មោះរបស់គាត់នៅក្នុងបញ្ជីបោះឆ្នោតដំបូងនៃការិយាល័យបោះឆ្នោតណាមួយនៅក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ ឬបែរជាមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូងនៃការិយាល័យបោះឆ្នោតនៅក្រុង ស្រុក ខណ្ឌ ផ្សេងទៅវិញ
- សាមីអ្នកប្ដឹងតវ៉ាជាសមាជិក កបឃ.ស នៅក្នុងមុខតំណែង មានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង ប៉ុន្តែឈ្មោះ ឬ/និងទិន្នន័យពាក់ព័ន្ធរបស់គាត់ ដែលបានបញ្ចូលទៅក្នុងបញ្ជីបោះឆ្នោតដំបូង មានភាពមិនច្បាស់លាស់ ឬមិនដូចគ្នានឹងទិន្នន័យក្នុង អ.ខ ឬ បណ្ណសម្គាល់ខ្លួនសមាជិក កបឃ.ស របស់គាត់។

**ពាក្យបណ្ដឹងជំទាស់** អាចធ្វើឡើងចំពោះបុគ្គលណាម្នាក់ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង ក្នុងករណី ៖

- ជននោះគ្មានសិទ្ធិបោះឆ្នោត ដោយសារមិនមែនជាសមាជិក កបឃ.ស នៅក្នុងមុខតំណែងក្នុងក្របខណ្ឌនៃក្រុង ស្រុក ខណ្ឌនីមួយៗ
- សាមីគណបក្សនយោបាយបានស្នើសុំប្ដូរឈ្មោះអ្នកបោះឆ្នោត ដោយសារអ្នកបោះឆ្នោតនោះ បាត់បង់មុខតំណែងជាសមាជិក កបឃ.ស នៅក្នុងក្របខណ្ឌក្រុង ស្រុក ខណ្ឌ
- ជននោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោតច្រើនជាងមួយកន្លែង។

## ១. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គឃ.ខប

### ១.១ ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គឃ.ខប

ក. អ្នកប្ដឹងត្រូវបំពេញ ទ.១២០២។ ក្នុងករណីដែលអ្នកប្ដឹងមកប្ដឹងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរតាមលិខិតផ្សេងក្រៅពី ទ.១២០២ គឃ.ខប ត្រូវណែនាំអ្នកប្ដឹងឱ្យបំពេញ ទ.១២០២ ចំនួន ៣ (បី) ច្បាប់ **(ករណីប្ដឹងតវ៉ា)** ឬ ៤ (បួន) ច្បាប់ **(ករណីប្ដឹងជំទាស់)**។

ខ. នៅពេលបានទទួលពាក្យបណ្ដឹង សមាជិក គឃ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួនជាអាទិ៍ ៖

១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង។

២- កម្មវត្ថុនៃពាក្យបណ្ដឹង និងការគោរពរយៈពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។

គ. បន្ទាប់មកសមាជិក គឃ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវធ្វើកំណត់ហេតុសាកសួរពីអ្នកប្ដឹង ឬតំណាងដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្ដឹង ឬតំណាងនោះចុះហត្ថលេខា ឬផ្ដិតមេដៃលើកំណត់ហេតុសាកសួរនេះ។ ក្នុងករណីអ្នកប្ដឹង ឬតំណាងមិនព្រមចុះហត្ថលេខា ឬផ្ដិតមេដៃ សមាជិក គឃ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមចុះហត្ថលេខា ឬផ្ដិតមេដៃលើកំណត់ហេតុនោះ។

ឃ. បន្ទាប់ពីបានពិនិត្យលើពាក្យបណ្ដឹង និងកំណត់ហេតុសាកសួរ ហើយឃើញថា ៖

ឃ.១ ពាក្យបណ្ដឹងមិនគោរពរយៈពេលកំណត់ ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ប្រធាន គឃ.ខប ឬសមាជិក គឃ.ខប ដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ថា "**ពាក្យបណ្ដឹងនេះបានដាក់ក្រោយរយៈពេលកំណត់ ដូចមានចែងក្នុងចំណុច ២.៦៤.៥ នៃ ប.ន.ក ដែលជាហេតុថ្លោះសិទ្ធិ[២]ក្នុងការប្ដឹងមក គឃ.ខប។ ដូចនេះ គឃ.ខប មិនអាចទទួលពាក្យបណ្ដឹងនេះមកពិនិត្យ និងដោះស្រាយ**

[២] ការបាត់បង់សិទ្ធិ ដោយហេតុមិនបានបំពេញលក្ខខណ្ឌដែលច្បាប់តម្រូវឱ្យបំពេញក្នុងរយៈពេលមានកំណត់

**បានឡើយ។**" ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ឃ.២** ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ដូចមានចែងក្នុង **ចំណុច ១ (ទំព័រ១)** ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទិ៍ សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមចំណុចខ្វះខាត ដោយមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយត្រូវកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត ប្រធាន គធ.ខប ឬសមាជិក គធ.ខប ដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ថា "**ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ...។ដូចនេះគធ.ខបមិនអាចទទួលពាក្យបណ្តឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ។**" ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ឃ.៣** ពាក្យបណ្តឹងគោរពរយៈពេលកំណត់ ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង មានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ (**ចំពោះសាមីខ្លួនដែលមិនចូលខ្លួនប្តឹងផ្ទាល់)** សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា ឈ្មោះ និងបោះត្រា គធ.ខប លើពាក្យបណ្តឹងគ្រប់ច្បាប់ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ)ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ១ (មួយ) ច្បាប់ **(ករណីប្តឹងជំទាស់)** ទុកប្រើក្នុងពេលសវនាការ ១ (មួយ) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់។

## ១.២ ការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប

**ក.** គធ.ខប ត្រូវសម្រេចលើពាក្យបណ្តឹងក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង។

**ខ.** ក្នុងករណីដែល គធ.ខប ប្រជុំសម្រេចបដិសេធពាក្យបណ្តឹង គធ.ខប ត្រូវធ្វើលិខិតជូនដំណឹងតាមលិខិតរដ្ឋបាល ដោយបញ្ជាក់ពីមូលហេតុដែលមិនអាចទទួលយកមកដោះស្រាយបានទៅអ្នកប្តឹង ឬតំណាង ហើយប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ប្រគល់ជូនអ្នកត្រូវគេប្តឹង ១ (មួយ) ច្បាប់ **(ករណីប្តឹងជំទាស់)** ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**គ.** ក្នុងករណីដែល គធ.ខប សម្រេចបើកសវនាការយល់ព្រម ឬបដិសេធលើពាក្យបណ្តឹង គធ.ខប ត្រូវចេញសេចក្តីសម្រេច (ទ.១២០៣) ចំនួន ៣ (បី) ច្បាប់ **(ករណីប្តឹងតវ៉ា)** ឬចំនួន ៤ (បួន) ច្បាប់ **(ករណីប្តឹងជំទាស់)**។ ទ.១២០៣ ត្រូវចុះហត្ថលេខាដោយលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឈ្មោះ ហើយបោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ប្រគល់ជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ **(ករណីប្តឹងជំទាស់)** ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ឃ.** គធ.ខប ត្រូវប្រកាន់យកលក្ខខណ្ឌសម្រាប់ការចុះឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែង ដូចមានចែងក្នុង ច.ប.ក ប.ន.ក ធ្វើជាមូលដ្ឋានសម្រេចលើពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់។

**ង.** ប្រធាន កបឃ.ស ឬតំណាងដែលត្រូវបានប្រគល់សិទ្ធិអាចមានវត្តមាននៅក្នុងការបើកសវនាការរបស់ គធ.ខប ដើម្បីផ្តល់ព័ត៌មានដោយចំហពាក់ព័ន្ធនឹងពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ជូន គធ.ខប ។

**ច.** បន្ទាប់ពី គធ.ខប បើកសវនាការលើពាក្យបណ្តឹងតវ៉ា ក្នុងករណីដែល ៖

- **បដិសេធលើពាក្យបណ្តឹងតវ៉ា ៖** គធ.ខប ជម្រាបអ្នកប្តឹងថា គាត់អាចប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់ គធ.ខប ទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣។
- **យល់ព្រមលើពាក្យបណ្តឹងតវ៉ា ៖** គធ.ខប ធ្វើរបាយការណ៍ផ្ញើជូន គ.ជ.ប ដោយភ្ជាប់មកជាមួយ ទ.១២០៣ ដើម្បីសុំបញ្ចូលឈ្មោះ ឬកែតម្រូវទិន្នន័យក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

ឆ. បន្ទាប់ពី គធ.ខប បើកសវនាការលើពាក្យបណ្ដឹងជំទាស់ ក្នុងករណីដែល ៖
  - **បដិសេធលើពាក្យបណ្ដឹងជំទាស់ ៖** គធ.ខប ជម្រាបអ្នកប្ដឹងថា គាត់អាចប្ដឹងជំទាស់ទៅនឹងសេចក្ដីសម្រេចរបស់ គធ.ខប ទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣។
  - **យល់ព្រមលើពាក្យបណ្ដឹងជំទាស់ ៖** គធ.ខប ជូនដំណឹងទៅអ្នកដែលត្រូវគេប្ដឹងជំទាស់ថា គាត់អាចប្ដឹងតវ៉ាទៅនឹងសេចក្ដីសម្រេចរបស់ គធ.ខប ទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ ព្រមទាំងធ្វើរបាយការណ៍ផ្ញើជូន គ.ជ.ប ដោយភ្ជាប់មកជាមួយ ទ.១២០៣។

ជ. សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប ត្រូវអនុវត្តតាមលក្ខខណ្ឌ**ដូចមានចែងក្នុងជំពូកទី២ ផ្នែកទី១ នៃសៀវភៅណែនាំនេះ (ទំព័រ៥៣ ដល់ទំព័រ៥៥)**។

## ២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប

### ២.១ ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គ.ជ.ប

ក. អ្នកប្ដឹងតវ៉ា ឬអ្នកប្ដឹងជំទាស់ ឬអ្នកត្រូវគេប្ដឹងជំទាស់ ឬតំណាងដែលមិនសុខចិត្តនឹងលិខិតជូនដំណឹង ឬសេចក្ដីសម្រេចរបស់ គធ.ខប មានសិទ្ធិប្ដឹងទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប ។

ខ. អ្នកប្ដឹង ឬតំណាងត្រូវបំពេញ ទ.១២០២ ចំនួន ៣ (បី) ច្បាប់ **(ករណីប្ដឹងតវ៉ា)** ឬចំនួន ៤ (បួន) ច្បាប់ **(ករណីប្ដឹងជំទាស់)**។

គ. នៅពេលបានទទួលពាក្យបណ្ដឹង មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន ជាអាទិ៍ ៖
  - **១-** ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬតំណាង។
  - **២-** កម្មវត្ថុនៃពាក្យបណ្ដឹង និងការគោរពរយៈពេលកំណត់ ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប ។

ឃ. បន្ទាប់មកមន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវធ្វើកំណត់ហេតុសាកសួរពីអ្នកប្ដឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្ដឹង ឬតំណាងចុះហត្ថលេខា ឬផ្ដិតមេដៃលើកំណត់ហេតុនេះ។ ក្នុងករណីអ្នកប្ដឹង ឬតំណាងមិនព្រមចុះហត្ថលេខា ឬផ្ដិតមេដៃ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមចុះហត្ថលេខា ឬផ្ដិតមេដៃលើកំណត់ហេតុនោះ។

ង. បន្ទាប់ពីបានពិនិត្យលើពាក្យបណ្ដឹង និងកំណត់ហេតុសាកសួរ ហើយឃើញថា ៖

ង.១ ពាក្យបណ្ដឹងមិនគោរពរយៈពេលកំណត់ ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ឃប គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ថា "**ពាក្យបណ្ដឹងនេះបានដាក់ក្រោយរយៈពេលកំណត់ ដូចមានចែងក្នុងចំណុច ២.៦៥.១៨ នៃ ប.ន.ក ដែលជាហេតុផ្ដាច់សិទ្ធិក្នុងការប្ដឹងមក គ.ជ.ប ។ ដូចនេះ គ.ជ.ប មិនអាចទទួលពាក្យបណ្ដឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ។**" ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

ង.២ ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ **ដូចមានចែងក្នុងចំណុច ១ (ទំព័រ១)** ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទិ៍ **(ចំពោះសាមីខ្លួនដែលមិនចូលខ្លួនប្ដឹងផ្ទាល់)** មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវណែនាំអ្នកប្ដឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ហើយត្រូវកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់អ្នកប្ដឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ថា "**ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ...។ ដូចនេះ គ.ជ.ប មិនអាចទទួលពាក្យបណ្ដឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ។**" ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

ង.៣ ពាក្យបណ្ដឹងគោរពរយៈពេលកំណត់ ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ឃប មានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ **(ចំពោះសាមីខ្លួនដែលមិនចូលខ្លួនប្ដឹងផ្ទាល់)** មន្ត្រីជំនាញនៃ

នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា ឈ្មោះ លើពាក្យបណ្តឹងគ្រប់ច្បាប់ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ **(ករណីប្តឹងជំទាស់)** រក្សាទុកប្រើក្នុងពេលសវនាការ ១ (មួយ) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់។

## ២.២ ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

**ក.** គ.ជ.ប ត្រូវសម្រេចលើពាក្យបណ្តឹងក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង។

**ខ.** ក្នុងករណីដែល គ.ជ.ប ប្រជុំសម្រេចបដិសេធពាក្យបណ្តឹង គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាល ដោយបញ្ជាក់ពីមូលហេតុដែលមិនអាចទទួលយកមកដោះស្រាយបានទៅអ្នកប្តឹង ឬតំណាង ហើយប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ១ (មួយ) ច្បាប់ **(ករណីប្តឹងជំទាស់)** ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**គ.** ក្នុងករណីដែល គ.ជ.ប បើកសវនាការសង្ខេប ឬជាសាធារណៈសម្រេចយល់ព្រម ឬបដិសេធលើពាក្យបណ្តឹង គ.ជ.ប ត្រូវចេញ ទ.១២០៣ ចំនួន ៣ (បី) ច្បាប់ **(ករណីប្តឹងតវ៉ា)** ឬចំនួន ៤ (បួន) ច្បាប់ **(ករណីប្តឹងជំទាស់)**។ ទ.១២០៣ ត្រូវចុះហត្ថលេខាដោយប្រធានគណៈលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាប្រជុំជម្រះ ឈ្មោះ ហើយបោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ជូន ឬផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ **(ករណីប្តឹងជំទាស់)** ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកឯកសារ ១ (មួយ) ច្បាប់។

**ឃ.** បន្ទាប់ពី គ.ជ.ប បើកសវនាការសម្រេចលើពាក្យបណ្តឹងតវ៉ា ក្នុងករណីដែល ៖

- **បដិសេធលើពាក្យបណ្តឹងតវ៉ា ៖** គ.ជ.ប ជម្រាបអ្នកប្តឹងថា សេចក្តីសម្រេចរបស់ គ.ជ.ប ជាសេចក្តីសម្រេចចុងក្រោយបិទផ្លូវតវ៉ា។
- **យល់ព្រមលើពាក្យបណ្តឹងតវ៉ា ៖** គ.ជ.ប ចាត់ចែងអនុវត្តការចុះឈ្មោះបោះឆ្នោត ឬកែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត។

**ង.** បន្ទាប់ពី គ.ជ.ប បើកសវនាការសម្រេចលើពាក្យបណ្ដឹងជំទាស់ ក្នុងករណីដែល ៖

- **បដិសេធលើពាក្យបណ្ដឹងជំទាស់ ៖** គ.ជ.ប ជម្រាបអ្នកប្ដឹងថា សេចក្ដីសម្រេចរបស់ គ.ជ.ប ជាសេចក្ដីសម្រេចចុងក្រោយបិទផ្លូវតវ៉ា។
- **យល់ព្រមលើពាក្យបណ្ដឹងជំទាស់ ៖** គ.ជ.ប ត្រូវចាត់ ន.គ.ទ.ប ឱ្យលុបឈ្មោះអ្នកដែលត្រូវគេប្ដឹងជំទាស់ចេញពីបញ្ជីបោះឆ្នោតភ្លាម និងជម្រាបអ្នកត្រូវគេប្ដឹងជំទាស់ថា សេចក្ដីសម្រេចរបស់ គ.ជ.ប គឺជាសេចក្ដីសម្រេចចុងក្រោយបិទផ្លូវតវ៉ា។

**ច.** សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវអនុវត្តតាមលក្ខខណ្ឌ**ដូចមានចែងក្នុងជំពូកទី២ ផ្នែកទី១ នៃសៀវភៅណែនាំនេះ (ទំព័រ៥៤ ដល់ទំព័រ៥៥)។**

# ៣. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង

គំនូសបំព្រួញទី២

ក. ករណីពាក្យបណ្តឹងតវ៉ា



គំនូសបំព្រួញទី៣

ខ. ករណីពាក្យបណ្ដឹងជំទាស់



# ផ្នែកទី ៤
# ការអនុវត្តសេចក្ដីសម្រេចស្ថាពររបស់ គធ.ខប ឬសេចក្ដីសម្រេចស្ថាពររបស់ គ.ជ.ប ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង

សេចក្ដីសម្រេចស្ថាពររបស់ គធ.ខប ឬ គ.ជ.ប ត្រូវអនុវត្តដូចខាងក្រោម ៖

## ក. ការអនុវត្តសេចក្ដីសម្រេចស្ថាពររបស់ គធ.ខប

បន្ទាប់ពីបានទទួលរបាយការណ៍ដែលមានភ្ជាប់មកជាមួយ ទ.១២០៣ ទាក់ទងនឹងការយល់ព្រមរបស់ គធ.ខប លើពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ដែលបានចូលជាស្ថាពរហើយ ក្នុងករណីដែល ៖

- **យល់ព្រមលើពាក្យបណ្ដឹងតវ៉ា ៖** គ.ជ.ប ចាត់ឱ្យនាយកដ្ឋាន គ.ទ.ប បញ្ចូលឈ្មោះ ឬកែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធជាបន្ទាន់។
- **យល់ព្រមលើពាក្យបណ្ដឹងជំទាស់ ៖** គ.ជ.ប ចាត់ឱ្យនាយកដ្ឋាន គ.ទ.ប លុបឈ្មោះអ្នកដែលត្រូវគេប្ដឹងជំទាស់ចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោត ឬប្ដូរឈ្មោះអ្នកបោះឆ្នោតដែលបាត់បង់មុខតំណែងជាសមាជិក កបឃ.ស នៅក្នុងក្របខណ្ឌក្រុង ស្រុក ខណ្ឌពាក់ព័ន្ធជាបន្ទាន់។

## ខ. ការអនុវត្តសេចក្ដីសម្រេចស្ថាពររបស់ គ.ជ.ប

បន្ទាប់ពី ទ.១២០៣ របស់ គ.ជ.ប បានចូលជាស្ថាពរហើយ ក្នុងករណីដែល ៖

- **យល់ព្រមលើពាក្យបណ្ដឹងតវ៉ា ៖** គ.ជ.ប ចាត់ឱ្យនាយកដ្ឋាន គ.ទ.ប បញ្ចូលឈ្មោះ ឬកែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធជាបន្ទាន់។
- **យល់ព្រមលើពាក្យបណ្ដឹងជំទាស់ ៖** គ.ជ.ប ចាត់ឱ្យនាយកដ្ឋាន គ.ទ.ប លុបឈ្មោះអ្នកដែលត្រូវគេប្ដឹងជំទាស់ចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោត ឬប្ដូរឈ្មោះអ្នកបោះឆ្នោតដែលបាត់បង់មុខតំណែងជាសមាជិក កបឃ.ស នៅក្នុងក្របខណ្ឌក្រុង ស្រុក ខណ្ឌពាក់ព័ន្ធជាបន្ទាន់។

# ផ្នែកទី ៥
# នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង ចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី៣ថ្មី (អំពីទោសប្បញ្ញត្តិ) នៃ ច.ប.ក

ផ្នែកទី៥ នេះ ណែនាំអំពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី៣ថ្មី (អំពីទោសប្បញ្ញត្តិ) នៃ ច.ប.ក ដែលប្រព្រឹត្តដោយជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬប្រព្រឹត្តដោយគណបក្សនយោបាយ ឬប្រព្រឹត្តដោយជនដែលជាមន្ត្រីបោះឆ្នោតដែលអាចនាំឱ្យមានការពិន័យ និងដែលអាចកើតមានឡើងនៅគ្រប់ដំណាក់កាលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារួមទាំងនៅ១(មួយ)ថ្ងៃ មុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត។

## I. ពាក្យបណ្តឹងពាក់ព័ន្ធនឹងជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ

ជនណាក៏ដោយដែលរងឥទ្ធិពល ឬដែលស្ថិតនៅកន្លែងកើតហេតុ ឬតំណាងមានសិទ្ធិដាក់ពាក្យបណ្តឹងចំពោះជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយណាដែលល្មើសលើ ច.ប.ក ច.ប.ត.រ ច.វ.ច.ប ឬ ប.ន.ក ទៅ គធ.ខប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ។ ភាគី ឬតំណាងអាចប្តឹងបន្តទៅ គ.ជ.ប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប ។ ពាក្យបណ្តឹងត្រូវបញ្ជាក់ព័ត៌មានចាំបាច់មួយចំនួនដូចមានចែងក្នុង**ចំណុច ១ (ទំព័រ១)**។

## ១. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប

### ១.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គធ.ខប

**ក.** អ្នកប្តឹងត្រូវបំពេញ ទ.១២០២ ចំនួន ៤ (បួន) ច្បាប់។ អ្នកប្តឹងដំបូងអាចថតចម្លង ទ.១២០២ ដែលខ្លួនបានបំពេញ រួចចុះហត្ថលេខា ឬផ្តិតមេដៃលើច្បាប់ចម្លងទាំងនោះដោយខ្លួនឯង ហើយអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់ ឬអាចប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យតំណាងដាក់ពាក្យបណ្តឹងជូសខ្លួនបាន។

**ខ.** នៅពេលបានទទួលពាក្យបណ្តឹងសមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន ជាអាទិ៍ ៖

១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង។

២- កម្មវត្ថុនៃពាក្យបណ្តឹង និងការគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ។

គ. បន្ទាប់មកសមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវធ្វើកំណត់ហេតុសាកសួរពីអ្នកប្ដឹង ឬតំណាងដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្ដឹង ឬតំណាងចុះហត្ថលេខា ឬផ្ដិតមេដៃលើកំណត់ហេតុសាកសួរនេះ។ ក្នុងករណីអ្នកប្ដឹង ឬតំណាងមិនព្រមចុះហត្ថលេខា ឬផ្ដិតមេដៃ សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមចុះហត្ថលេខា ឬផ្ដិតមេដៃលើកំណត់ហេតុនោះ។

ឃ. បន្ទាប់ពីបានពិនិត្យលើពាក្យបណ្ដឹង និងកំណត់ហេតុសាកសួរ ហើយឃើញថា ៖

ឃ.១ ពាក្យបណ្ដឹងមិនគោរពរយៈពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ ប្រធាន គធ.ខប ឬសមាជិក គធ.ខប ដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ថា "**ពាក្យបណ្ដឹងនេះបានដាក់ក្រោយរយៈពេលកំណត់ដូចមានចែងក្នុងប្រការ ២.១៥២ នៃ ប.ន.ក ដែលជាហេតុផ្ដាច់សិទ្ធិក្នុងការប្ដឹងមក គធ.ខប ។ ដូចនេះ គធ.ខប មិនអាចទទួលពាក្យបណ្ដឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ។**" ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

ឃ.២ ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ដូចមានចែងក្នុង **ចំណុច ១ (ទំព័រ១)** ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទិ៍ សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវណែនាំអ្នកប្ដឹង ឬតំណាងឱ្យបំពេញបន្ថែមចំណុចខ្វះខាត ដោយមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ហើយត្រូវកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់អ្នកប្ដឹង ឬតំណាងមិនបានបំពេញបន្ថែមនូវ

ចំណុចខ្វះខាត ប្រធាន គធ.ខប ឬសមាជិក គធ.ខប ដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ថា "**ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ...។ ដូចនេះ គធ.ខប មិនអាចទទួលពាក្យបណ្ដឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ។**" ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

**ឃ.៣** ពាក្យបណ្ដឹងគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ មានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ **(ចំពោះសាមីខ្លួនដែលមិនចូលខ្លួនប្ដឹងផ្ទាល់)** សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវចុះកាលបរិច្ឆេទ ពេលវេលា និងចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប លើពាក្យបណ្ដឹងគ្រប់ច្បាប់ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ១ (មួយ) ច្បាប់ រក្សាទុកប្រើក្នុងពេលប្រជុំផ្សះផ្សា ១ (មួយ) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់។

## ១.២ ការដោះស្រាយពាក្យបណ្ដឹងនៅ គធ.ខប

**ក.** បន្ទាប់ពីបានទទួលពាក្យបណ្ដឹងហើយ គធ.ខប ត្រូវប្រជុំពិភាក្សាដើម្បីពិនិត្យសម្រេចជាបន្ទាន់លើពាក្យបណ្ដឹង។ ក្នុងករណី គធ.ខប ពិនិត្យ និងយល់ឃើញថា ៖

**ក.១** ពាក្យបណ្ដឹងគ្មានមូលដ្ឋានពាក់ព័ន្ធនឹងការបំពានលើបទប្បញ្ញត្តិនៃ ច.ប.ក ឬ ច.ប.ត.រ ឬ ច.រ.ច.ប ឬ ប.ន.ក ទេ គធ.ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្ដឹង ឬតំណាងដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ក.២** កម្មវត្ថុ និងមូលហេតុនៃពាក្យបណ្ដឹងមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌសុទ្ធសាធ មិនពាក់ព័ន្ធទៅនឹងការបំពានលើបទប្បញ្ញត្តិនៃ ច.ប.ក ឬ ច.ប.ត.រ ឬ ច.រ.ច.ប ឬ ប.ន.ក ទេ គធ.ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្ដឹង ឬតំណាង ដោយបញ្ជាក់ថា "**ពាក្យបណ្ដឹងនេះ គធ.ខប មិនអាចទទួលមកដោះស្រាយបានទេ ដោយហេតុថា ករណីនេះ ឬទាំងនេះ គឺជាបទល្មើសព្រហ្មទណ្ឌ ពុំមែនជាសមត្ថកិច្ចរបស់ គធ.ខប ។**" ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ក.៣** ពាក្យបណ្ដឹងមានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងមានព័ត៌មានចាំបាច់ គធ.ខប ត្រូវបង្កើតក្រុមត្រួតពិនិត្យ និងស្រាវជ្រាវ ដែលអាចមានសមាសភាព ដូចខាងក្រោម ៖

- ប្រធាន គធ.ខប ឬតំណាង ជាប្រធានក្រុម
- សមាជិក គធ.ខប ១ (មួយ) នាក់ ជាសមាជិក
- សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ១ (មួយ) នាក់ ជាលេខាធិការ។

**ខ.** ក្រុមត្រួតពិនិត្យ និងស្រាវជ្រាវត្រូវបើកការស៊ើបអង្កេតជាបន្ទាន់ដោយសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត និងអាជ្ញាធរពាក់ព័ន្ធនានាដើម្បីចុះត្រួតពិនិត្យ និងកត់ត្រាកំណត់ហេតុដល់ទីកន្លែងកើតហេតុ ប្រមូលភស្តុតាង សាកសួរសាក្សី និងជនដែលពាក់ព័ន្ធក្នុងពាក្យបណ្ដឹង។ ប្រធានក្រុមត្រួតពិនិត្យ និងស្រាវជ្រាវនេះ អាចស្នើសុំ និងអនុញ្ញាតឱ្យអ្នកប្ដឹង ឬតំណាងអមដំណើរជាមួយ បើមានការយល់ព្រមពីអ្នកប្ដឹង ឬតំណាង។

**គ.** បន្ទាប់ពីក្រុមត្រួតពិនិត្យ និងស្រាវជ្រាវស៊ើបអង្កេតចប់សព្វគ្រប់ ហើយលទ្ធផលបង្ហាញថា ជនដែលត្រូវគេប្ដឹងចោទប្រកាន់នោះមិនបានបំពានលើបទប្បញ្ញត្តិនៃ ច.ប.ក ឬ ច.ប.ត.រ ឬ ច.រ.ច.ប ឬ ប.ន.ក ទេ គធ.ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្ដឹង ឬតំណាង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ផ្ញើជូនអ្នកត្រូវគេប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ឃ. ក្នុងករណីលទ្ធផលនៃការស៊ើបអង្កេតបង្ហាញថា ជនដែលត្រូវប្ដឹងចោទប្រកាន់នោះបានបំពានលើបទប្បញ្ញត្តិនៃ ច.ប.ក ឬ ច.ប.ត.រ ឬ ច.វ.ច.ប ឬ ប.ន.ក **គធ.ខប ត្រូវអញ្ជើញភាគីទំនាស់ទាំងអស់មកធ្វើការផ្សះផ្សាតាមថ្ងៃ និងពេលវេលា សមស្របជាបន្ទាន់កំណត់ដោយ គធ.ខប ។**

ង. គធ.ខប ត្រូវធ្វើកំណត់ហេតុប្រជុំផ្សះផ្សា ដោយឱ្យគូភាគីផ្ដិតមេដៃលើកំណត់ហេតុប្រជុំផ្សះផ្សានោះ។

ច. ក្នុងការប្រជុំផ្សះផ្សា ប្រសិនបើភាគីទំនាស់ ៖

ច.១ **ព្រមព្រៀងគ្នា** គធ.ខប ត្រូវកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សានោះឱ្យបានច្បាស់ថា ភាគីទំនាស់យល់ព្រមសះជានឹងគ្នា ដោយឱ្យភាគីទំនាស់ផ្ដិតមេដៃលើកំណត់ហេតុប្រជុំផ្សះផ្សានោះ បន្ទាប់មកត្រូវបញ្ជូនកំណត់ហេតុប្រជុំផ្សះផ្សានោះ ជាបន្ទាន់មក គ.ជ.ប ។

ច.២ **មិនព្រមព្រៀងគ្នាទេ** គធ.ខប ត្រូវកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សានោះឱ្យបានច្បាស់ថា ភាគីទំនាស់មិនព្រមសះជានឹងគ្នាទេ។ គធ.ខប ត្រូវកំណត់ពេលវេលា និងកាលបរិច្ឆេទបើកសវនាការជាសាធារណៈ ក្នុងរយៈពេល ១ (មួយ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃផ្សះផ្សា ហើយជូនដំណឹងភ្លាមនៅនឹងកន្លែងប្រជុំផ្សះផ្សាទៅភាគីពាក់ព័ន្ធឱ្យបានដឹងពីពេលវេលា កាលបរិច្ឆេទ និងទីកន្លែងបើកសវនាការតែម្ដង។

ឆ. គធ.ខប ត្រូវបើកសវនាការជាសាធារណៈសម្រេចយល់ព្រម ឬបដិសេធលើពាក្យបណ្ដឹង ដោយមានកំណត់ហេតុសវនាការ សេចក្ដីសម្រេច និង ទ.១២០៣ ចំនួន ៤ (បួន) ច្បាប់ ដោយមានការចុះហត្ថលេខា ឈ្មោះរបស់លេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយបោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ប្រគល់ជូនអ្នកត្រូវគេប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ជ. សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប ត្រូវអនុវត្តតាមលក្ខខណ្ឌ**ដូចមានចែងក្នុងជំពូកទី២ ផ្នែកទី១ នៃសៀវភៅណែនាំនេះ (ទំព័រ៥៣ ដល់ទំព័រ៥៥)**។

## ២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

### ២.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គ.ជ.ប

ក. ភាគីវិវាទ ឬតំណាងដែលមិនសុខចិត្តនឹងលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប អាចប្តឹងទៅ គ.ជ.ប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប ។ អ្នកប្តឹង ឬតំណាងត្រូវបំពេញ ទ.១២០២ ចំនួន ៤ (បួន) ច្បាប់។

ខ. នៅពេលបានទទួលពាក្យបណ្តឹង មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន ជាអាទិ៍ ៖

១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង។

២- កម្មវត្ថុនៃពាក្យបណ្តឹង និងការគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប ។

គ. បន្ទាប់មកមន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវធ្វើកំណត់ហេតុសាកសួរពីអ្នកប្តឹង ឬតំណាងដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុនេះ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុនោះ។

ឃ. បន្ទាប់ពីបានពិនិត្យលើពាក្យបណ្តឹង និងកំណត់ហេតុសាកសួរ ហើយឃើញថា ៖

ឃ.១ ពាក្យបណ្តឹងមិនគោរពរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ថា "**ពាក្យបណ្តឹងនេះបានដាក់ក្រោយរយៈពេលកំណត់ដែលជាហេតុផ្លោះសិទ្ធិក្នុងការប្តឹងមក គ.ជ.ប ។ ដូចនេះ គ.ជ.ប មិនអាចទទួលពាក្យបណ្តឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ។**" ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

**ឃ.២** ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ដូចមានចែងក្នុង **ចំណុច ១ (ទំព័រ១)** ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទិ៍ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវណែនាំអ្នកប្ដឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ហើយត្រូវកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្ដឹងឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ថា "**ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ...។ ដូចនេះ គ.ជ.ប មិនអាចទទួលពាក្យបណ្ដឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ។**" ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

**ឃ.៣** ពាក្យបណ្ដឹងគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប មានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមតាមច្បាប់ **(ចំពោះសាមីខ្លួនដែលមិនចូលខ្លួនប្ដឹងផ្ទាល់)** មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះកាលបរិច្ឆេទពេលវេលា និងចុះហត្ថលេខា ឈ្មោះ លើពាក្យបណ្ដឹងគ្រប់ច្បាប់ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ១ (មួយ) ច្បាប់ និងរក្សាទុកប្រើក្នុងពេលសវនាការ ១ (មួយ) ច្បាប់ និងបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់។

## ២.២ ការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប

**ក.** បន្ទាប់ពីបានទទួលពាក្យបណ្ដឹងហើយ គ.ជ.ប ត្រូវពិនិត្យជាបន្ទាន់លើពាក្យបណ្ដឹង។ ក្នុងករណី គ.ជ.ប ពិនិត្យ និងយល់ឃើញថា ៖

**ក.១** ពាក្យបណ្តឹងគ្មានមូលដ្ឋានពាក់ព័ន្ធនឹងការបំពានលើបទប្បញ្ញត្តិនៃ ច.ប.ក ឬ ច.ប.ត.រ ឬ ច.វ.ច.ប ឬ ប.ន.ក ទេ គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ឬតំណាង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ឃប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ក.២** កម្មវត្ថុ និងមូលហេតុនៃពាក្យបណ្តឹងមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌសុទ្ធសាធ មិនពាក់ព័ន្ធទៅនឹងការបំពានលើបទប្បញ្ញត្តិនៃ ច.ប.ក ឬ ច.ប.ត.រ ឬ ច.វ.ច.ប ឬ ប.ន.ក ទេ គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ឬតំណាង ដោយបញ្ជាក់ថា **“ពាក្យបណ្តឹងនេះមិនអាចដោះស្រាយបានទេ ដោយហេតុថាករណីនេះ ឬទាំងនេះគឺជាបទល្មើសព្រហ្មទណ្ឌ ពុំមែនជាសមត្ថកិច្ចរបស់ គ.ជ.ប ។”** ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ឃប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ក.៣** ពាក្យបណ្តឹងដែលត្រូវបានភាគីទំនាស់សះជានឹងគ្នារួចហើយនៅ គធ.ឃប គ.ជ.ប ត្រូវពិនិត្យ សម្រេចថាត្រូវដោះស្រាយសាជាថ្មី ឬសម្រេចបដិសេធ។ ក្នុងករណីបដិសេធ គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ឬតំណាង ដោយបញ្ជាក់ថា **“ពាក្យបណ្តឹងនេះ ភាគីទំនាស់បានសះជានឹងគ្នារួចហើយ ហើយគ្មានហេតុផលថ្មីផ្សេងទៀត ដូចនេះ គ.ជ.ប មិនអាចទទួលពាក្យបណ្តឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ។”** ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ឃប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ក.៤** ពាក្យបណ្តឹងមានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងមានព័ត៌មានចាំបាច់ គ.ជ.ប ត្រូវកំណត់នីតិវិធីដោះស្រាយ។

**ខ.** គ.ជ.ប អាចបើកការស៊ើបអង្កេតជាបន្ទាន់ ចំពោះករណីណាដែលយល់ថាជាការចាំបាច់ និងស្មុគស្មាញ។

**គ.** បន្ទាប់ពីបានធ្វើការស៊ើបអង្កេតចប់សព្វគ្រប់ គ.ជ.ប មានសិទ្ធិមិនយកពាក្យបណ្តឹងនោះមកបើកសវនាការដោះស្រាយ ប្រសិនបើយល់ឃើញថាពាក្យបណ្តឹងផ្ទុយនឹងទម្រង់ ឬគតិច្បាប់ ឬ/និងមិនមានអំណះអំណាងណាមួយពាក់ព័ន្ធនឹងកម្មវត្ថុនៃពាក្យបណ្តឹង ដែលអាចយកមកដោះស្រាយបាន ឬ/និងអំណះអំណាងមិនច្បាស់លាស់ ឬ/និងតាមការស៊ើបអង្កេតស្រាវជ្រាវរបស់ គ.ជ.ប ឃើញថា ផ្ទុយពីការអះអាងក្នុងពាក្យបណ្តឹង។ ការបដិសេធមិនទទួលដោះស្រាយរបស់ គ.ជ.ប ត្រូវធ្វើតាមរយៈលិខិតជូនដំណឹងបដិសេធតាមបែបបទរដ្ឋបាល ក្នុងរយៈពេលសមស្របមួយទៅអ្នកប្តឹង ឬតំណាង ដើម្បីជូនជ្រាបថាពាក្យបណ្តឹងរបស់គាត់ មិនត្រូវបានយកមកដោះស្រាយទេ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ឃ.** បន្ទាប់ពីបានធ្វើការស៊ើបអង្កេតចប់សព្វគ្រប់ ប្រសិនបើ គ.ជ.ប រកឃើញភស្តុតាងពាក់ព័ន្ធនឹងកម្មវត្ថុនៃពាក្យបណ្តឹង គ.ជ.ប ត្រូវសម្រេចដោះស្រាយពាក្យបណ្តឹងតាមពេលវេលាសមស្របជាបន្ទាន់។

**ង.** ប្រសិនបើ គ.ជ.ប សម្រេចបើកសវនាការយល់ព្រម ឬបដិសេធលើពាក្យបណ្តឹង សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវធ្វើឡើងដោយផ្អែកតាមកំណត់ហេតុសវនាការ ហើយត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ។ សេចក្តីសម្រេចនេះត្រូវស្រង់ដាក់ក្នុង ទ.១២០៣ ចំនួន ៤ (បួន) ច្បាប់ ដោយមានចុះហត្ថលេខា ឈ្មោះ របស់ប្រធានគណៈលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយបោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចគណៈលេខាធិការសវនាការត្រូវប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ប្រគល់ជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ច.** សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវអនុវត្តតាមលក្ខខណ្ឌ**ដូចមានចែងក្នុងជំពូកទី២ ផ្នែកទី១ នៃសៀវភៅណែនាំនេះ (ទំព័រ៥៤ ដល់ទំព័រ៥៥)**។

**ឆ.** សេចក្តីសម្រេចរបស់ គ.ជ.ប ជាសេចក្តីសម្រេចចុងក្រោយបិទផ្លូវតវ៉ា។

## ៣. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង ពាក់ព័ន្ធនឹងជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ



## II. ពាក្យបណ្តឹងពាក់ព័ន្ធនឹងជនដែលជាមន្ត្រីបោះឆ្នោត

គ្រប់ពាក្យបណ្តឹងពាក់ព័ន្ធនឹងអំពើបំពានលើបទប្បញ្ញត្តិនៃ ច.ប.ក ឬ ច.ប.ត.រ ឬ ច.វ.ច.ប ឬ ប.ន.ក ឬបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ដែលប្តឹង គ.ក.ប/គ.ក.រ ឬ គធ.ខប ឬមន្ត្រីបោះឆ្នោតត្រូវដាក់ទៅថ្នាក់លើមួយថ្នាក់ ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ។

គ្រប់ពាក្យបណ្តឹងពាក់ព័ន្ធនឹងអំពើបំពានលើបទប្បញ្ញត្តិនៃ ច.ប.ក ឬ ច.ប.ត.រ ឬ ច.វ.ច.ប ឬ ប.ន.ក ឬបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ដែលប្រព្រឹត្តដោយមន្ត្រីបោះឆ្នោត ត្រូវអនុវត្តលក្ខខណ្ឌនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង **ដូចមានចែងក្នុងផ្នែកទី៥ ចំណុច I នៃសៀវភៅណែនាំនេះ (ទំព័រ២៣ ដល់ទំព័រ៣១)**។

**ក.** ពាក្យបណ្តឹងពាក់ព័ន្ធនឹងសមាសភាព គ.ក.ប/គ.ក.រ ដំបូងត្រូវប្តឹងទៅ គធ.ខប តាមលក្ខខណ្ឌ**ដូចបានណែនាំក្នុងសៀវភៅណែនាំនេះ (ទំព័រ២៣ ដល់ទំព័រ៣១)**។

**ខ.** ពាក្យបណ្តឹងពាក់ព័ន្ធនឹងសមាសភាព គធ.ខប ឬមន្ត្រី លគធ.ខប ឬ មន្ត្រី គ.ជ.ប ត្រូវប្តឹងទៅ គ.ជ.ប តាមលក្ខខណ្ឌ**ដូចបានណែនាំក្នុងសៀវភៅណែនាំនេះ (ទំព័រ២៨ ដល់ទំព័រ៣១)**។

**គ.** ពាក្យបណ្តឹងពាក់ព័ន្ធនឹង គ.ជ.ប ត្រូវប្តឹងទៅរដ្ឋសភា ដោយអនុលោមតាម ច.គ.ជ.ប ។

**ឃ.** ពាក្យបណ្តឹងចោទប្រកាន់សមាជិក ឬមន្ត្រីដែលបដិសេធមិនទទួលយកពាក្យបណ្តឹងដោយគ្មានមូលហេតុ និងគតិច្បាប់ត្រឹមត្រូវ ឬ/និងមិនព្រមដោះស្រាយពាក្យបណ្តឹងដែលសមាជិក ឬមន្ត្រីនោះបានទទួលពាក្យបណ្តឹងរួចហើយត្រូវដាក់ពាក្យបណ្តឹងទៅថ្នាក់លើមួយថ្នាក់ ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ។

**ករណីដែលរកឃើញថា ៖**

- សមាជិក ឬមន្ត្រីនោះពិតជាបានបំពានលើបទប្បញ្ញត្តិនៃ ច.ប.ក ឬ ច.ប.ត.រ ឬ ច.វ.ច.ប ឬ ប.ន.ក ប្រាកដមែន សមាជិក ឬមន្ត្រីនោះត្រូវទទួលទណ្ឌកម្មផ្នែកវិន័យ ស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប
- សមាជិក ឬមន្ត្រីនោះបានគោរពតាមបទប្បញ្ញត្តិនៃ ច.ប.ក ឬ ច.ប.ត.រ ឬ ច.វ.ច.ប ឬ ប.ន.ក ឬបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ត្រឹមត្រូវហើយ គ.ជ.ប ត្រូវបដិសេធពាក្យបណ្តឹងនោះ ហើយពាក្យបណ្តឹងដែលត្រូវបានបដិសេធមិនដោះស្រាយនោះ ក៏ត្រូវបដិសេធផងដែរ។

# គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង ពាក់ព័ន្ធនឹងជនដែលជាមន្ត្រីបោះឆ្នោត

គំនូសបំព្រួញទី៥



# ផ្នែកទី៦
# នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង ពាក់ពន្ធ័នឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងភាពមិនប្រក្រតីនៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត ព្រមទាំងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត

ផ្នែកទី ៦ នេះ ណែនាំអំពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងពាក់ព័ន្ធនឹងភាពមិនប្រក្រតីណាមួយដែលកើតមានឡើង ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ពាក្យបណ្ដឹងពាក់ព័ន្ធនឹងភាពមិនប្រក្រតីដែលកើតមានឡើងក្នុងតំបន់ណាមួយនៅ ១ (មួយ) ថ្ងៃមុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត និងពាក្យបណ្ដឹងទាក់ទងនឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត។

## ១. ការតវ៉ា ឬការជំទាស់ និងការដោះស្រាយនៅ គ.ក.ប/គ.ក.រ

### ១.១ ការតវ៉ា ឬការជំទាស់នៅ គ.ក.ប/គ.ក.រ

**ក.** ភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិតវ៉ា ឬជំទាស់នឹងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងរាប់សន្លឹកឆ្នោត ឬភាពមិនប្រក្រតីនៃការបោះឆ្នោត ឬ/និងសេចក្ដីសម្រេចណាមួយរបស់ គ.ក.ប/គ.ក.រ នៅការិយាល័យបោះឆ្នោត ឬរាប់សន្លឹកឆ្នោតដែលខ្លួនបំពេញការងារសង្កេតការណ៍ ដោយផ្ទាល់មាត់ភ្លាមៗទៅប្រធាន គ.ក.ប/គ.ក.រ ។

**ខ.** ភ្នាក់ងារគណបក្សនយោបាយត្រូវបង្ហាញអំពីមូលហេតុ ឬ/និងភស្ដុតាងដែលនាំឱ្យប្រធាន គ.ក.ប/គ.ក.រ ជឿថាមានភាពមិនប្រក្រតី ឬមានការបំពានច្បាប់ ឬ/និង ប.ន.ក នៅការិយាល័យបោះឆ្នោត ឬការិយាល័យរាប់សន្លឹកឆ្នោតនោះ។

### ១.២ ការដោះស្រាយចំពោះការតវ៉ា ឬការជំទាស់នៅ គ.ក.ប/គ.ក.រ

**ក.** ប្រធាន គ.ក.ប/គ.ក.រ ត្រូវធ្វើការដោះស្រាយភ្លាមនូវការតវ៉ា ឬការជំទាស់របស់ភ្នាក់ងារគណបក្សនយោបាយនោះ។

**ខ.** ប្រសិនបើយល់ឃើញថា ការតវ៉ា ឬការជំទាស់នោះមានលក្ខណៈសមហេតុផល ប្រធាន គ.ក.ប/គ.ក.រ ត្រូវបញ្ឈប់ជាបណ្ដោះអាសន្ននូវកិច្ចប្រតិបត្តិការបោះឆ្នោត ឬរាប់សន្លឹកឆ្នោត ដើម្បីស្ដាប់ការតវ៉ា ឬការជំទាស់របស់ភ្នាក់ងារគណបក្សនយោបាយនោះ ហើយបន្ទាប់មកពិភាក្សាបញ្ហានេះជាមួយនឹងសមាជិក គ.ក.ប/គ.ក.រ ដទៃទៀត ដើម្បីដោះស្រាយភាពមិនប្រក្រតីទាំងនោះជាបន្ទាន់។

គ. បន្ទាប់ពីពិនិត្យឡើងវិញអំពីករណី ដែលបានលើកការតវ៉ា ឬការជំទាស់ ប្រសិនបើប្រធាន គ.ក.ប/គ.ក.រ យល់ព្រមតាមការតវ៉ា ឬការជំទាស់ ប្រធាន គ.ក.ប/គ.ក.រ ត្រូវណែនាំ និងរំលឹកដល់សមាជិក គ.ក.ប/គ.ក.រ និងអ្នកមានវត្តមានផ្សេងទៀតក្នុងការិយាល័យបោះឆ្នោត ឬការិយាល័យរាប់សន្លឹកឆ្នោត អំពីខ្លឹមសារពាក់ព័ន្ធដូចមានចែងក្នុង ច.ប.ក ច.ប.គ.រ ច.វ.ច.ប និង ប.ន.ក ហើយត្រូវរិះរកវិធីណាមួយដើម្បីដោះស្រាយភាពមិនប្រក្រតីនោះជាបន្ទាន់។

ឃ. ប្រសិនបើយល់ឃើញថា ការតវ៉ា ឬ/និងការជំទាស់នោះ មិនសមហេតុផល ប្រធាន គ.ក.ប/គ.ក.រ មានសិទ្ធិបដិសេធការតវ៉ា ឬការជំទាស់របស់ភ្នាក់ងារគណបក្សនយោបាយនោះ ៖

ឃ.១ ក្នុងការបដិសេធការតវ៉ា ឬការជំទាស់ ប្រធាន គ.ក.ប/គ.ក.រ ត្រូវផ្តល់ហេតុផលពាក់ព័ន្ធនឹងការបដិសេធនោះ។ ភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិសុំឱ្យកត់ត្រាការតវ៉ា ឬការជំទាស់ក្នុងកំណត់ហេតុនៃការបោះឆ្នោត ឬការរាប់សន្លឹកឆ្នោត ប្រសិនបើភ្នាក់ងារគណបក្សនយោបាយ យល់ព្រមចុះហត្ថលេខាលើកំណត់ហេតុ។

ឃ.២ ប្រសិនបើភ្នាក់ងារគណបក្សនយោបាយនោះ មិនយល់ព្រមចុះហត្ថលេខាទេនោះ ប្រធាន គ.ក.ប/គ.ក.រ មិនចាំបាច់កត់ត្រាអំពីការតវ៉ា ឬការជំទាស់នោះក្នុងកំណត់ហេតុនៃការបោះឆ្នោត ឬការរាប់សន្លឹកឆ្នោតទេ។

ឃ.៣ ប្រសិនបើមានការស្នើសុំ ប្រធាន គ.ក.ប/គ.ក.រ ត្រូវផ្តល់ ទ.១២០២ ចំនួន ៣ (បី) ច្បាប់ ដល់ភ្នាក់ងារគណបក្សនយោបាយនោះ ដើម្បីប្តឹងបន្តទៅ គធ.ខប ។

ង. ការសម្រេចរបស់ប្រធាន គ.ក.ប/គ.ក.រ ត្រូវតែមានប្រសិទ្ធភាពក្នុងកម្រិតសមត្ថកិច្ចរបស់ខ្លួន ហើយប្រធាន គ.ក.ប/គ.ក.រ ត្រូវប្រកាសបន្តដំណើរការបោះឆ្នោត ឬរាប់សន្លឹកឆ្នោតតទៅទៀត។

ច. ការកំណត់ដូចមានចែងក្នុង**ចំណុច ង (ទំព័រ៣៦)** ខាងលើ មិនច្រានចោលដំណើរហេតុដែលភ្នាក់ងារគណបក្សនយោបាយណាម្នាក់ចង់បន្តប្តឹងតវ៉ា ឬប្តឹងជំទាស់ ទៅ គធ.ខប អំពីករណីនៃការតវ៉ា ឬការជំទាស់របស់ខ្លួនដូចមានចែងក្នុង**ចំណុច ក (ទំព័រ៣៥)** ខាងលើនោះទេ ប៉ុន្តែក្នុងស្ថានភាពនេះ ភ្នាក់ងារគណបក្សនយោបាយនោះ ត្រូវតែយល់ព្រមទទួលយកវិធានការនៃការគ្រប់គ្រងរបស់ប្រធាន គ.ក.ប/គ.ក.រ និងមិនត្រូវរំខាន ឬជ្រៀតជ្រែកធ្វើឱ្យរាំងស្ទះដល់កិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងរាប់សន្លឹកឆ្នោតឡើយ។

## ២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប

### ២.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គធ.ខប

**ក.** ភ្នាក់ងារគណបក្សនយោបាយ ដែលមិនសុខចិត្តនឹងការសម្រេចរបស់ប្រធាន គ.ក.ប/គ.ក.រ ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងរាប់សន្លឹកឆ្នោត ដូចមានចែងក្នុង**ចំណុច ង (ទំព័រ៣៦)** ខាងលើ មានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ាទៅ គធ.ខប ក្នុងរយៈពេលយ៉ាងយូរ ២ (ពីរ) ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត។

**ខ.** ជនដែលមានសិទ្ធិបោះឆ្នោតក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬភ្នាក់ងារគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះ ដែលមិនសុខចិត្ត មានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់ទៅ គធ.ខប អំពីលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតាមប្រភេទនីមួយៗ ក្នុងរយៈពេលយ៉ាងយូរ ២ (ពីរ) ថ្ងៃ បន្ទាប់ពីថ្ងៃបិទផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

**គ.** ប្រសិនបើក្នុងរយៈពេលដែលបានកំណត់ខាងលើ គធ.ខប មិនបានទទួលពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ណាមួយទេ ចាត់ទុកថាគ្មានការប្តឹងតវ៉ា ឬប្តឹងជំទាស់ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ឬលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត។

**ឃ.** ពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ដូចមានចែងក្នុង**ចំណុច ក និង ខ (ទំព័រ៣៧)** ខាងលើ ជាពាក្យបណ្តឹងទាក់ទងដល់ការសុំកែតម្រូវលើលទ្ធផលនៃការបោះឆ្នោត ហើយមានកម្មវត្ថុនៃពាក្យបណ្តឹងចំនួន ៣ (បី) ប្រភេទផ្សេងគ្នាដូចខាងក្រោម ៖

- ការស្នើសុំកែតម្រូវតួលេខលទ្ធផលនៃការបោះឆ្នោត
- ការស្នើសុំរាប់សន្លឹកឆ្នោតឡើងវិញ
- ការស្នើសុំឱ្យមានការបោះឆ្នោតសាជាថ្មី។

**ង.** អ្នកប្តឹងត្រូវបំពេញ និងចុះហត្ថលេខា ឬផ្តិតមេដៃលើ ទ.១២០២ ចំនួន ៣ (បី) ច្បាប់។

**ច.** ពាក្យបណ្តឹងត្រូវបញ្ជាក់ព័ត៌មានចាំបាច់មួយចំនួនដូចខាងក្រោម ៖

**១-** ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង។

**២-** លក្ខណៈសម្គាល់នៃការិយាល័យបោះឆ្នោត។

**៣-** ពេលវេលា និងទីកន្លែងកើតឡើងនូវភាពមិនប្រក្រតី។

៤- ប្រភេទនៃភាពមិនប្រក្រតី ឬកំហុសឆ្គងដែលជាកម្មវត្ថុនៃពាក្យបណ្តឹង។
៥- បើអាចធ្វើបាន ត្រូវបញ្ជាក់អំពីមាត្រានៃ ច.ប.ក ឬ ច.ប.ត.រ ឬ ច.វ.ច.ប ឬប្រការនៃ ប.ន.ក ដែលត្រូវបានរំលោភ។
៦- ជនដែលពាក់ព័ន្ធនឹងការប្តឹងតវ៉ា ឬការប្តឹងជំទាស់។
៧- ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី (ប្រសិនបើមាន)។
៨- សេចក្តីអះអាងគាំទ្រ ឬភស្តុតាងផ្សេងៗទៀត (ប្រសិនបើមាន)។
៩- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកសង្កេតការណ៍ ដែលមានវត្តមានក្នុងពេលហេតុការណ៍កើតឡើង (ប្រសិនបើមាន)។

**ឆ.** នៅពេលបានទទួលពាក្យបណ្តឹងសមាជិក គធ.ឃប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន មានជាអាទិ៍ ៖
១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង។
២- កម្មវត្ថុនៃពាក្យបណ្តឹង និងការគោរពរយៈពេលកំណត់ ២ (ពីរ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបោះឆ្នោត ឬ/និងរាប់សន្លឹកឆ្នោត ឬបន្ទាប់ពីថ្ងៃបិទផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោត។

**ជ.** បន្ទាប់មកសមាជិក គធ.ឃប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវធ្វើកំណត់ហេតុសាកសួរពីអ្នកប្តឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់រួចឱ្យអ្នកប្តឹង ឬតំណាងចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុសាកសួរនេះ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃ សមាជិក គធ.ឃប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុនោះ។

**ឈ.** បន្ទាប់ពីបានពិនិត្យលើពាក្យបណ្តឹង និងកំណត់ហេតុសាកសួរ ហើយឃើញថា ៖

**ឈ.១** ពាក្យបណ្តឹងមិនគោរពរយៈពេលកំណត់ ២ (ពីរ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬបន្ទាប់ពីថ្ងៃបិទផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ប្រធាន គធ.ឃប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរត្រូវចារបដិសេធ

លើពាក្យបណ្តឹងគ្រប់ច្បាប់ថា "**ពាក្យបណ្តឹងនេះបានដាក់ក្រោយរយៈពេលកំណត់ ដែលជាហេតុធ្លោះសិទ្ធិក្នុងការប្តឹងមក គធ.ខប ។ ដូចនេះ គធ.ខប មិនអាចទទួលពាក្យបណ្តឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ**"។ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ឈ.២ ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ដូចមានចែងក្នុង **ចំណុច ច (ទំព័រ៣៧)** ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទិ៍ សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមចំណុចខ្វះខាត ដោយមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយត្រូវកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត ប្រធាន គធ.ខប ឬសមាជិក គធ.ខប ដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ថា "**ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ...។ ដូចនេះ គធ.ខប មិនអាចទទួលពាក្យបណ្តឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ។**" ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ឈ.៣ ពាក្យបណ្តឹងគោរពរយៈពេលកំណត់ ២ (ពីរ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬបន្ទាប់ពីថ្ងៃបិទផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត មានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ **(ចំពោះសាមីខ្លួនដែលមិនចូលខ្លួនប្តឹងផ្ទាល់)** សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវចុះកាលបរិច្ឆេទពេលវេលា និងចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប លើ

ពាក្យបណ្ដឹងគ្រប់ច្បាប់ រួចជម្រាបអ្នកប្ដឹង ឬតំណាងថា គធ.ឧប នឹងដោះស្រាយពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ក្នុង រយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ រក្សាទុកក្នុងពេល ដោះស្រាយបណ្ដឹង ១ (មួយ) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់។

## ២.២ ការដោះស្រាយពាក្យបណ្ដឹងនៅ គធ.ឧប

**ក.** គធ.ឧប ត្រូវសម្រេចលើពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ទៅនឹងការសម្រេចរបស់ប្រធាន គ.ក.ប/គ.ក.រ ឬទៅនឹងលទ្ធផលបណ្ដោះអាសន្នតាមការិយាល័យបោះឆ្នោត ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង។

**ខ.** ក្នុងករណីពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់គ្មានភស្តុតាងបញ្ជាក់ ដែលអាចឱ្យជឿថាមានកំហុសធ្ងន់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងរាប់សន្លឹកឆ្នោត ឬ/និងពាក់ព័ន្ធនឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ គធ.ឧប ត្រូវបដិសេធពាក្យបណ្ដឹងនោះ និងចាត់ចែងត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតគ្រប់ការិយាល័យបោះឆ្នោតទាំងអស់ក្នុងរាជធានី ខេត្តជាធម្មតាតាមការកំណត់របស់ គ.ជ.ប ។ បន្ទាប់មកប្រធាន គធ.ឧប ត្រូវ ៖

**ខ.១** ចាត់មន្ត្រី លគធ.ឧប ឱ្យបំពេញ ទ.១២០៣ ចំនួន ៣ (បី) ច្បាប់ ហើយត្រូវចុះហត្ថលេខា ឈ្មោះ ដោយមន្ត្រី លគធ.ឧប និងប្រធាន គធ.ឧប បន្ទាប់មកចុះកាលបរិច្ឆេទ និងបោះត្រា គធ.ឧប ។

**ខ.២** ប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ខ.៣** ជម្រាបអ្នកប្ដឹង ឬតំណាងថា គាត់អាចប្ដឹងតវ៉ាទៅនឹងសេចក្ដីសម្រេចរបស់ គធ.ឧប ទៅ គ.ជ.ប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ ។

**ខ.៤** ប្រគល់ជូនអ្នកប្ដឹង ឬតំណាងនូវ ទ.១២០២ សម្រាប់បំពេញពាក្យបណ្ដឹងចំនួន ៣ (បី) ច្បាប់ ប្រសិនបើគាត់ស្នើសុំ។

**គ.** ក្នុងករណីពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់មានភស្តុតាងបញ្ជាក់ដែលអាចជឿថាមានកំហុសឆ្គងក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងរាប់សន្លឹកឆ្នោត ឬ/និងពាក់ព័ន្ធនឹងលទ្ធផលបណ្តោះអាសន្ននៅការិយាល័យបោះឆ្នោតណាមួយ ប្រធាន គធ.ខប ត្រូវ ៖

**គ.១** ចាត់ចែងត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតដែលមានពាក្យបណ្តឹង។

**គ.២** បើកកញ្ចប់សុវត្ថិភាព "ក៨" ឬកញ្ចប់សុវត្ថិភាព "ក៦" ដើម្បីធ្វើការត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ដោយត្រូវអនុវត្តនីតិវិធីដែលមានចែងក្នុង ប.ន.ក ។

**គ.៣** អនុញ្ញាតឱ្យអ្នកប្តឹង ឬតំណាង តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ចូលរួមសង្កេតមើលដំណើរការត្រួតពិនិត្យបញ្ជាក់ និងការរាប់សន្លឹកឆ្នោតខាងលើនេះ។

**ឃ.** ក្នុងករណីចាំបាច់ គធ.ខប អាចបើកការស៊ើបអង្កេតស្រាវជ្រាវលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ដើម្បីមានមូលដ្ឋានក្នុងការសម្រេចឱ្យបើក ឬមិនឱ្យបើកកញ្ចប់សុវត្ថិភាព "ក"។

**ង.** ប្រសិនបើក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ដូចមានចែងក្នុង**ចំណុច គ (ទំព័រ៤១)** ខាងលើ គធ.ខប មិនឃើញមានកំហុសឆ្គង ឬភាពមិនប្រក្រតីណាមួយដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយទេ គធ.ខប ត្រូវប្រជុំសម្រេចបដិសេធលើពាក្យបណ្តឹងនោះដោយមានកំណត់ហេតុផង ។ ក្នុងករណីនេះប្រធាន គធ.ខប ត្រូវ ៖

**ង.១** ចាត់មន្ត្រី លគធ.ខប ឱ្យបំពេញ ទ.១២០៣ ចំនួន ៣ (បី) ច្បាប់ ហើយត្រូវចុះហត្ថលេខា ឈ្មោះ ដោយមន្ត្រី លគធ.ខប និងប្រធាន គធ.ខប បន្ទាប់មកចុះកាលបរិច្ឆេទ និងបោះត្រា គធ.ខប ។

**ង.២** ប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ង.៣** ជម្រាបអ្នកប្តឹង ឬតំណាងថា គាត់អាចប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់ គធ.ខប ទៅ គ.ជ.ប ក្នុងរយៈពេល ៣ (បី) ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ ។

**ង.៤** ប្រគល់ជូនអ្នកប្តឹង ឬតំណាងនូវ ទ.១២០២ សម្រាប់បំពេញពាក្យបណ្តឹងចំនួន ៣ (បី) ច្បាប់ **(ករណីប្តឹងតវ៉ា)** ឬចំនួន ៤ (បួន) ច្បាប់ **(ករណីប្តឹងជំទាស់)** ប្រសិនបើគាត់ស្នើសុំ។

**ច.** ប្រសិនបើក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ដូចមានចែងក្នុង**ចំណុច គ (ទំព័រ៤១)** ខាងលើ គធ.ខប បានរកឃើញភស្តុតាងបញ្ជាក់ថាមានកំហុសឆ្គងក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងរាប់សន្លឹកឆ្នោត ឬមានភាពមិនប្រក្រតីធ្ងន់ធ្ងរដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ គធ.ខប ត្រូវសម្រេចយល់ព្រមលើពាក្យបណ្តឹងនោះដោយមានកំណត់ហេតុផង។ ក្នុងករណីនេះ ប្រធានក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប ត្រូវ ៖

**ច.១** ចាត់មន្ត្រី លគធ.ខប ឱ្យបំពេញ ទ.១២០៣ យល់ព្រមតាមពាក្យបណ្តឹងដោយធ្វើការកែតម្រូវតួលេខ ឬព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ។ ក្នុងករណី គធ.ខប សម្រេចថាព្យួរលទ្ធផលនៃការបោះឆ្នោត គធ.ខប ត្រូវធ្វើរបាយការណ៍លើកយោបល់អំពីករណីនេះជូន គ.ជ.ប ពិនិត្យសម្រេច បន្ទាប់មកត្រូវវេចខ្ចប់សម្ភារ ឯកសារពាក់ព័ន្ធដូចជា ទ.១២០៣ និងរបាយការណ៍ស្តីពីការព្យួរលទ្ធផលនេះដោយឡែក និងចាត់ចែងបញ្ជូនមក គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ២៤ (ម្ភៃបួន) ម៉ោង បន្ទាប់ពីការសម្រេចរបស់ គធ.ខប ។

**ច.២** ចុះហត្ថលេខា បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទលើ ទ.១២០៣ ដែលលេខាធិការបានបំពេញ រួចប្រគល់ជូនអ្នកប្តឹង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ច.៣** ប្រកាសថាសេចក្តីសម្រេចរបស់ គធ.ខប ដែលបានព្យួរលទ្ធផលស្ថិតក្រោមការត្រួតពិនិត្យសម្រេចឡើងវិញរបស់ គ.ជ.ប ។

## ៣. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

### ៣.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គ.ជ.ប

**ក.** ជនដែលមានសិទ្ធិបោះឆ្នោតក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬតំណាងគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះ ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចបដិសេធរបស់ គធ.ខប លើពាក្យបណ្តឹងរបស់ខ្លួន

ពាក់ព័ន្ធនឹងកំហុសឆ្គងក្នុងកិច្ចប្រតិប្រត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬអំពើរំលោភ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីណាមួយដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត ដូចមានចែងក្នុង **ចំណុច ខ** និង **ចំណុច ង (ទំព័រ៤០ ដល់ទំព័រ៤១)** ខាងលើ ឬជំទាស់នឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឬ/និងរាជធានី ខេត្ត មានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់ទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ បដិសេធពាក្យបណ្តឹងរបស់ គធ.ខប ឬបន្ទាប់ពីថ្ងៃ គធ.ខប បិទផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមប្រភេទក្រុមប្រឹក្សានីមួយៗ។

**ខ.** ប្រសិនបើនៅក្នុងរយៈពេលកំណត់ខាងលើ គ.ជ.ប មិនបានទទួលពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ណាមួយទេ ត្រូវចាត់ទុកថាគ្មានការប្តឹងទៅនឹងសេចក្តីសម្រេចរបស់ គធ.ខប ឬទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយឡើយ។

**គ.** អ្នកប្តឹង ឬតំណាងត្រូវបំពេញ ទ.១២០២ ចំនួន ៣ (បី) ច្បាប់។

**ឃ.** នៅពេលបានទទួលពាក្យបណ្តឹង មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន ជាអាទិ៍ ៖

**១-** ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង។

**២-** កម្មវត្ថុនៃពាក្យបណ្តឹង និងការគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ របស់ គធ.ខប ឬបន្ទាប់ពីថ្ងៃ គធ.ខប បិទផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមប្រភេទក្រុមប្រឹក្សានីមួយ។

**ង.** បន្ទាប់មកមន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវធ្វើកំណត់ហេតុសាកសួរពីអ្នកប្តឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុនេះ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុនោះ។

ច. បន្ទាប់ពីបានពិនិត្យលើពាក្យបណ្ដឹង និងកំណត់ហេតុសាកសួរ ហើយឃើញថា ៖

ច.១ ពាក្យបណ្ដឹងមិនគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ របស់ គធ.ខប ឬបន្ទាប់ពីថ្ងៃដែល គធ.ខប បិទផ្សាយលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមប្រភេទក្រុមប្រឹក្សានីមួយៗ គ.ជ.ប ត្រូវចារបដិសេធលើពាក្យ-បណ្ដឹងគ្រប់ច្បាប់ថា "**ពាក្យបណ្ដឹងនេះបានដាក់ក្រោយរយៈពេលកំណត់ ដែលជាហេតុផ្ដាច់សិទ្ធិក្នុងការប្ដឹងមក គ.ជ.ប ។ ដូចនេះ គ.ជ.ប មិនអាចទទួលពាក្យបណ្ដឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ។**" ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ច.២ ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ដូចមានចែងក្នុង **ចំណុច ច (ទំព័រ៣៧)** ខាងលើ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវណែនាំអ្នកប្ដឹង ឬតំណាងឱ្យបំពេញបន្ថែមចំណុចខ្វះខាតដោយមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្ដឹងហើយត្រូវកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្ដឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ថា "**ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ...។ ដូចនេះ គ.ជ.ប មិនអាចទទួលពាក្យបណ្ដឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ។**" ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ច.៣ ពាក្យបណ្ដឹងគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ របស់ គធ.ខប ឬបន្ទាប់ពីថ្ងៃ គធ.ខប បិទផ្សាយលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត តាមប្រភេទ

ក្រុមប្រឹក្សានីមួយៗ មានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ **(ចំពោះសាមីខ្លួនដែលមិនចូលខ្លួនប្ដឹងផ្ទាល់)** មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ចុះកាលបរិច្ឆេទ ពេលវេលា និងចុះហត្ថលេខា ឈ្មោះ លើពាក្យបណ្ដឹងគ្រប់ច្បាប់ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ រក្សាទុកប្រើពេលដោះស្រាយពាក្យបណ្ដឹង ១ (មួយ) ច្បាប់ និងបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់ ព្រមទាំងជម្រាបអ្នកប្ដឹង ឬតំណាងថា គ.ជ.ប នឹងដោះស្រាយពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់នេះ ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង និងបន្ទាប់ពីក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប បានបញ្ចប់ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធនឹងពាក្យបណ្ដឹងនេះ។

## ៣.២ ការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប

**ក.** គ.ជ.ប ត្រូវធ្វើការសម្រេចលើពាក្យបណ្ដឹងទាំងនោះ ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹងស្របតាម ច.ប.ក ប.ន.ក និងតាមការកំណត់របស់ គ.ជ.ប ។

**ខ.** នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស ត្រូវរាយការណ៍ជាបន្ទាន់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ អំពីករណីនៃពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ដោយភ្ជាប់ពាក្យបណ្ដឹងដែលបានទទួល និង ទ.១២០៣ របស់ គជ.ខប ដែលត្រូវបានដកចេញពីកញ្ចប់ "ឃ ពិសេស" ដើម្បីសុំការណែនាំពី គ.ជ.ប សម្រេចកំណត់អំពីករណីនៃការត្រួតពិនិត្យ និងបញ្ជាក់លទ្ធផល និងអំពីភាពចាំបាច់ ឬមិនចាំបាច់ឱ្យបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ។ ផ្អែកតាមការណែនាំរបស់ គ.ជ.ប អគ្គលេខាធិការ គ.ជ.ប ត្រូវចាត់ចែងក្រុមត្រួតពិនិត្យ និងបញ្ជាក់លទ្ធផលឱ្យធ្វើការត្រួតពិនិត្យ និងបញ្ជាក់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធនឹងពាក្យបណ្ដឹងនោះ នៅចំពោះមុខតំណាងគណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍ និងអ្នកប្ដឹង ឬតំណាង។

**គ.** ផ្អែកតាមការសម្រេចរបស់ គ.ជ.ប មិនឱ្យបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោត

ឡើងវិញទេ អគ្គលេខាធិការ គ.ជ.ប ត្រូវណែនាំក្រុមត្រួតពិនិត្យលទ្ធផល នៃ គ.ជ.ប ត្រូវពិនិត្យជាមុនសេចក្តីសម្រេចរបស់ គធ.ខប (ករណីមានពាក្យបណ្តឹងនៅ គធ.ខប) ហើយត្រូវត្រួតពិនិត្យលទ្ធផលជាធម្មតាតាមបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ។ ផ្អែកតាមរបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផលដែលមានចំណាររបស់អគ្គលេខាធិការ គ.ជ.ប ស្នើសុំយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត ឬកែតម្រូវតួលេខលទ្ធផល (ករណីពាក្យបណ្តឹងអំពីកំហុសក្នុងការគណនាលេខ) គ.ជ.ប ត្រូវប្រជុំសម្រេចលើពាក្យបណ្តឹងនោះ។ ប្រសិនបើ គ.ជ.ប យល់ព្រមតាមយោបល់របស់អគ្គលេខាធិការ គ.ជ.ប ប្រធាន គ.ជ.ប ត្រូវ ៖

- **គ.១** ចារយល់ព្រមលើ ទ.១២០៣ របស់ គធ.ខប ដែលយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធ ឬយល់ព្រមកែតម្រូវតួលេខលទ្ធផល ព្រមទាំងចុះហត្ថលេខា ឈ្មោះ ចុះកាលបរិច្ឆេទ និងបោះត្រា គ.ជ.ប ។
- **គ.២** ចារយល់ព្រមលើរបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប ព្រមទាំងចុះហត្ថលេខា ឈ្មោះ ចុះកាលបរិច្ឆេទ និងបោះត្រា គ.ជ.ប ។
- **គ.៣** ចាត់មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ឱ្យបំពេញ ទ.១២០៣ ទទួលយកលទ្ធផលនៃការបោះឆ្នោត ឬកែតម្រូវ តួលេខលទ្ធផល ហើយចុះហត្ថលេខា ឈ្មោះ ចុះកាលបរិច្ឆេទ និងបោះត្រា គ.ជ.ប រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ផ្ញើជូនគ្រប់តំណាងគណបក្សនយោបាយ ដែលមានបញ្ជីបេក្ខជនឈរឈ្មោះក្នុងមណ្ឌលបោះឆ្នោតពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ឃ.** ផ្អែកតាមការសម្រេចរបស់ គ.ជ.ប ឱ្យបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ អគ្គលេខាធិការត្រូវណែនាំក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប ត្រួតពិនិត្យជាមុនពាក្យបណ្តឹងពាក់ព័ន្ធដែលដាក់នៅ គ.ជ.ប និងសេចក្តីសម្រេចរបស់ គធ.ខប (ប្រសិនបើមានពាក្យបណ្តឹងដាក់នៅ គធ.ខប) ហើយត្រូវអនុវត្តនីតិវិធីត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោត គួបផ្សំនឹងនីតិវិធីដែលរាប់សន្លឹកឆ្នោតឡើងវិញ ដូចមានចែងក្នុង ប.ន.ក (ប្រសិនបើមានពាក្យបណ្តឹងសុំឱ្យរាប់សន្លឹកឆ្នោតឡើងវិញ)។

**ឃ.១** ផ្អែកតាមរបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផលដែលមានចំណាររបស់អគ្គលេខាធិការ គ.ជ.ប ស្នើសុំបដិសេធលទ្ធផលនៃការបោះឆ្នោត ដោយសារមានភាពមិនប្រក្រតីធ្ងន់ធ្ងរដែលនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត (ករណីពាក្យបណ្ដឹងសុំឱ្យរៀបចំការបោះឆ្នោតសាជាថ្មី) ឬកែតម្រូវតួលេខលទ្ធផល (ករណីពាក្យបណ្ដឹងអំពីកំហុសក្នុងការគណនាលេខ ឬសុំឱ្យរាប់សន្លឹកឆ្នោតឡើងវិញ) ហើយប្រសិនបើ គ.ជ.ប យល់ព្រមតាមយោបល់របស់អគ្គលេខាធិការ ប្រធាន គ.ជ.ប ត្រូវ ៖

- ចារបដិសេធលើ ទ.១២០៣ របស់ គធ.ខប (ប្រសិនបើមានពាក្យបណ្ដឹងដាក់នៅ គធ.ខប) ដែលយល់ព្រមទទួលយកលទ្ធផល ហើយចុះហត្ថលេខា ឈ្មោះ ចុះកាលបរិច្ឆេទ និងបោះត្រា គ.ជ.ប ។
- ចាត់មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ឱ្យបំពេញ ទ.១២០៣ បដិសេធលទ្ធផលនៃការបោះឆ្នោត (ករណីពាក្យបណ្ដឹងសុំឱ្យបោះឆ្នោតសាជាថ្មី) ឬកែតម្រូវតួលេខ (ករណីពាក្យបណ្ដឹងអំពីកំហុសក្នុងការគណនាលេខ ឬសុំឱ្យរាប់សន្លឹកឆ្នោតឡើងវិញ) ហើយចុះហត្ថលេខា ឈ្មោះ ចុះកាលបរិច្ឆេទ និងបោះត្រា គ.ជ.ប បន្ទាប់មកប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនគ្រប់គណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះក្នុងមណ្ឌលបោះឆ្នោតពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។
- ប្រកាសថា គ.ជ.ប នឹងចាត់ចែងឱ្យរៀបចំការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ក្នុងរយៈពេលយ៉ាងយូរ ៨ (ប្រាំបី) ថ្ងៃ គិតចាប់ពីថ្ងៃចេញ ទ.១២០៣ បដិសេធលទ្ធផលនៃការបោះឆ្នោតនោះ។

**ឃ.២** ផ្អែកតាមរបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផលដែលមានចំណាររបស់អគ្គលេខាធិការ គ.ជ.ប ស្នើសុំយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត ហើយប្រសិនបើ គ.ជ.ប យល់ព្រមតាមយោបល់របស់អគ្គលេខាធិការ ប្រធាន គ.ជ.ប ត្រូវចាត់ចែងអនុវត្តតាមលំនាំនីតិវិធីដូចមានចែងក្នុង**ចំណុច គ (ទំព័រ៤៥)** ខាងលើ (ចំពោះករណីយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត)។

**ង.** សេចក្ដីសម្រេចរបស់ គ.ជ.ប ជាសេចក្ដីសម្រេចចុងក្រោយបិទផ្លូវតវ៉ា។

## ៣.៣ ការត្រួតពិនិត្យលទ្ធផលដែល គធ.ខប បានសម្រេចព្យួរជាបណ្ដោះអាសន្ន

**ក.** គ.ជ.ប ត្រូវធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាដែល គធ.ខប សម្រេចព្យួរជាបណ្ដោះអាសន្ន ក្នុងរយៈពេលយ៉ាងយូរ ៤ (បួន) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្ដីសម្រេចបដិសេធលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយ ឬនៅការិយាល័យបោះឆ្នោតណាមួយ។

**ខ.** គ.ជ.ប ត្រូវសម្រេចអំពីភាពចាំបាច់ ឬមិនចាំបាច់បើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតសម្រាប់ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាដែលស្ថិតក្នុងករណី គធ.ខប ព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោត។

**ខ.១** ក្នុងករណី គ.ជ.ប សម្រេចមិនឱ្យបើកកញ្ចប់សុវត្ថិភាព "ក" ទេ អគ្គលេខាធិការ គ.ជ.ប ត្រូវណែនាំក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប ឱ្យធ្វើការត្រួតពិនិត្យលទ្ធផល ដោយផ្អែកលើរាល់សំណុំឯកសារដែលមានក្នុងស្រោមសំបុត្រធំប៉ុណ្ណោះ។

**ខ.២** ក្នុងករណី គ.ជ.ប សម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព "ក" អគ្គលេខាធិការ គ.ជ.ប ត្រូវណែនាំក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប ឱ្យធ្វើការត្រួតពិនិត្យលទ្ធផលដោយផ្អែកលើរាល់សំណុំឯកសារដែលមានក្នុងស្រោមសំបុត្រធំ និងត្រូវអនុវត្តបន្ថែមការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដូចមានចែងក្នុង ប.ន.ក ។

**គ.** ផ្អែកលើរបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផលដែលមានចំណាររបស់អគ្គលេខាធិការ គ.ជ.ប ស្នើសុំយល់ព្រមតាមសេចក្ដីសម្រេចរបស់ គធ.ខប ព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោត ប្រសិនបើមានភាពមិនប្រក្រតីធ្ងន់ធ្ងរដែលនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត ឬស្នើសុំបដិសេធសេចក្ដីសម្រេចរបស់ គធ.ខប ព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោត ហើយក្នុងករណីដែល គ.ជ.ប ៖

គ.១ យល់ព្រមតាមសេចក្ដីសម្រេចរបស់ គធ.ខប ប្រធាន គ.ជ.ប ត្រូវ ៖

- ចារយល់ព្រមលើ ទ.១២០៣ ព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតរបស់ គធ.ខប ហើយចុះហត្ថលេខា ឈ្មោះ ចុះកាលបរិច្ឆេទ និងបោះត្រា គ.ជ.ប ។
- ចារយល់ព្រមលើរបាយការណ៍របស់អគ្គលេខាធិការ ដែលស្នើសុំយល់ព្រមតាមសេចក្ដីសម្រេចរបស់ គធ.ខប និងចារបដិសេធលើតារាងត្រួតពិនិត្យលទ្ធផល (ទ.១១១៧ គពស ឬ ទ.១១១៧ គពខ) ហើយចុះហត្ថលេខា ឈ្មោះ ចុះកាលបរិច្ឆេទ និងបោះត្រា គ.ជ.ប ។
- ចាត់មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ឱ្យបំពេញ ទ.១២០៣ បដិសេធលទ្ធផលនៃការបោះឆ្នោត ហើយចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ជូនគ្រប់តំណាងគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះនៅមណ្ឌលបោះឆ្នោតពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។
- ប្រកាសថា គ.ជ.ប នឹងចាត់ចែងឱ្យរៀបចំការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ក្នុងរយៈពេលយ៉ាងយូរ ៨ (ប្រាំបី) ថ្ងៃ គិតចាប់ពីថ្ងៃចេញ ទ.១២០៣ បដិសេធលទ្ធផលនៃការបោះឆ្នោតនោះ។

គ.២ មិនយល់ព្រមតាមសេចក្ដីសម្រេចរបស់ គធ.ខប ប្រធាន គ.ជ.ប ត្រូវ ៖

- ចារបដិសេធលើ ទ.១២០៣ ព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតរបស់ គធ.ខប ហើយចុះហត្ថលេខា និងកាលបរិច្ឆេទ។
- ចារយល់ព្រមលើរបាយការណ៍របស់អគ្គលេខាធិការ ដែលស្នើសុំបដិសេធសេចក្ដីសម្រេចរបស់ គធ.ខប និងចារយល់ព្រមលើតារាងត្រួតពិនិត្យលទ្ធផល (ទ.១១១៧ គពស ឬ ទ.១១១៧ គពខ) ហើយចុះហត្ថលេខា និងកាលបរិច្ឆេទ។

- ចាត់មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ឱ្យបំពេញ ទ.១២០៣ បដិសេធសេចក្តីសម្រេចរបស់ គធ.ខប ព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោត ហើយ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប រួចប្រគល់ ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ជូនគ្រប់តំណាង គណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះនៅ មណ្ឌលបោះឆ្នោតពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ឃ.** សេចក្តីសម្រេចរបស់ គ.ជ.ប ជាសេចក្តីសម្រេចចុងក្រោយបិទផ្លូវតវ៉ា។

**ង.** បន្ទាប់ពីបានដោះស្រាយពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ និង បន្ទាប់ពីបានអនុវត្តចប់សព្វគ្រប់រាល់នីតិវិធីនៃការត្រួតពិនិត្យឡើងវិញ នូវលទ្ធផលនៃការបោះឆ្នោតនៅ គ.ជ.ប រួមទាំងលទ្ធផលនៃការបោះឆ្នោត សាជាថ្មី (ប្រសិនបើមាន) គ.ជ.ប ត្រូវប្រកាសលទ្ធផលជាផ្លូវការនៃការ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។

## គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងទាក់ទងនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងភាពមិនប្រក្រតីនៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត ព្រមទាំងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត



# ផ្នែកទី ៧
# នីតិវិធីអនុវត្តសេចក្តីសម្រេចស្ថាពរចំពោះការដាក់ទណ្ឌកម្មពិន័យជាប្រាក់

សេចក្តីសម្រេចស្ថាពរដាក់ទណ្ឌកម្មពិន័យជាប្រាក់ទៅលើជនល្មើសត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ៖

**ក.** នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសនៃ គ.ជ.ប ជាអ្នកទទួលខុសត្រូវរៀបចំសំណុំឯកសារអនុវត្តសេចក្តីសម្រេចស្ថាពរ និងលើកសំណើតាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីដាក់ជូន គ.ជ.ប ពិនិត្យ និងសម្រេច។

**ខ.** ក្នុងការអនុវត្តសេចក្តីសម្រេចស្ថាពរ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវជូនដំណឹងទៅជនដែលត្រូវពិន័យ ឱ្យចូលខ្លួនមកអនុវត្តសេចក្តីសម្រេចដាក់ទណ្ឌកម្មពិន័យជាប្រាក់នោះដោយស្ម័គ្រចិត្ត ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានសេចក្តីបង្គាប់។

**គ.** បើដល់ពេលកំណត់ ជនដែលត្រូវពិន័យមិនព្រមបង់ប្រាក់ពិន័យតាមសេចក្តីជូនដំណឹងទេនោះ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវរៀបចំរបាយការណ៍ និងលើកសំណើតាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីដាក់ជូន គ.ជ.ប ពិនិត្យ និងសម្រេច។

**ឃ.** ក្នុងករណីដែល គ.ជ.ប យល់ឃើញថា គ្មានស្ថានភាពណាមួយដែល គ.ជ.ប ត្រូវពន្យារពេល ឬបន្ធូរបន្ថយ ឬលើកលែងទណ្ឌកម្មពិន័យជាប្រាក់ ឬរំលត់ការដាក់ទណ្ឌកម្មទេនោះ គ.ជ.ប អាចស្នើសុំអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដើម្បីអនុវត្តសេចក្តីសម្រេចស្ថាពររបស់ គ.ជ.ប ទារប្រាក់ពីជនដែលត្រូវពិន័យជូន គ.ជ.ប ។

**ង.** ប្រាក់ពិន័យដែលទទួលបាន ត្រូវបង់ចូលជាថវិការដ្ឋ។

# ជំពូកទី ២
# សមត្ថកិច្ចដោះស្រាយវិវាទក្នុងការបោះឆ្នោត
## ផ្នែកទី ១
## សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ

គជ.ខប និង គ.ជ.ប មានសិទ្ធិអំណាច និងភារកិច្ចសម្រេចលើពាក្យបណ្ដឹងដែលពាក់ព័ន្ធទៅនឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។ គជ.ខប បើកការប្រជុំផ្សះផ្សា ឬ/និងបើកសវនាការ និង គ.ជ.ប ពិនិត្យសម្រេច ឬបើកសវនាការលើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ទាក់ទងនឹងការបោះឆ្នោតនេះ លើកលែងតែពាក្យបណ្ដឹងដែលទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការ។

នីតិវិធីប្រជុំផ្សះផ្សា និងសវនាការដោះស្រាយពាក្យបណ្ដឹងដូចមានចែងក្នុងជំពូកនេះ ត្រូវយកមកអនុវត្តក្នុងគ្រប់ដំណាក់កាលទាំងអស់នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ដែលរួមមានដំណាក់កាលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ដំណាក់កាលចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ដំណាក់កាលឃោសនាបោះឆ្នោត ដំណាក់កាលនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងបិទផ្សាយលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត។

សេចក្ដីសម្រេចរបស់ គ.ជ.ប ជាសេចក្ដីសម្រេចចុងក្រោយបិទផ្លូវតវ៉ា។

### ១.សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ

ការប្រជុំផ្សះផ្សា ឬសវនាការ ត្រូវធ្វើឡើងដោយក្រុមប្រឹក្សាដែលត្រូវបានចាត់តាំងឱ្យចូលរួមដោយ គជ.ខប ឬ គ.ជ.ប ។

#### ១.១ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គជ.ខប

សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះដែលចាត់តាំងដោយ គជ.ខប ត្រូវអនុវត្តការប្រជុំផ្សះផ្សា ឬសវនាការ និងការសម្រេចរបស់ខ្លួនស្របតាមនីតិវិធីដោះស្រាយពាក្យបណ្ដឹង ដូចមានចែងក្នុង**ចំណុច ២.១ (ទំព័រ៥៥)** នៃសៀវភៅណែនាំនេះ។

ប្រធាន អនុប្រធាន និងសមាជិក គធ.ខប ដែលត្រូវបានចាត់តាំងឱ្យចូលរួមប្រជុំផ្សះផ្សា ហៅថា "**ក្រុមប្រឹក្សាប្រជុំផ្សះផ្សា**" ឬដែលត្រូវបានចាត់តាំងឱ្យចូលរួមសវនាការ ហៅថា "**ក្រុមប្រឹក្សាជំនុំជម្រះ**"។ សមាសភាពរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប រួមមាន ៖

- ប្រធាន គធ.ខប ឬតំណាង ជាប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- អនុប្រធាន និងសមាជិក គធ.ខប ជាសមាជិក
- មន្ត្រី លគធ.ខប ដែលត្រូវបានចាត់តាំង ជាលេខាធិការ។

កូរ៉ុម និងលក្ខខណ្ឌសុពលភាព នៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប ត្រូវអនុវត្តតាមសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិក គធ.ខប ទាំងមូល។

រាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប មិនត្រូវមានសំឡេងអនុបវាទឡើយ។

## ១.២ ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប

សមាសភាពក្រុមប្រឹក្សាជំនុំជម្រះដែលចាត់តាំងដោយ គ.ជ.ប ត្រូវអនុវត្តតាមការសម្រេចរបស់ គ.ជ.ប អនុលោមតាម ច.គ.ជ.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

ប្រធាន អនុប្រធាន និងសមាជិក គ.ជ.ប ដែលត្រូវបានចាត់តាំងឱ្យចូលរួមសវនាការដោះស្រាយពាក្យបណ្តឹង ហៅថា "**ក្រុមប្រឹក្សាជំនុំជម្រះ**" សមាសភាពរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប រួមមាន ៖

- ប្រធាន គ.ជ.ប ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- អនុប្រធាន និងសមាជិក គ.ជ.ប ជាសមាជិក
- មន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប ដែលត្រូវបានចាត់តាំង ជាគណៈ-លេខាធិការសវនាការ។

លក្ខខណ្ឌសុពលភាពនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវគោរពតាមបទប្បញ្ញត្តិនៃ ច.គ.ជ.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

រាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប មិនត្រូវមានសំឡេងអនុបវាទឡើយ។

## ២. សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ

### ២.១ សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប

ក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ គធ.ខប មានសិទ្ធិអំណាចកោះហៅគូភាគីឱ្យចូលខ្លួនមកបំភ្លឺក្នុងពេលប្រជុំផ្សះផ្សា។ ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប មានសិទ្ធិអំណាចកោះហៅគូភាគី និងសាក្សីឱ្យចូលខ្លួនមកបំភ្លឺក្នុងសវនាការ។

ក្នុងពេលប្រជុំផ្សះផ្សា ឬសវនាការ ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអនុញ្ញាតឱ្យជនណាម្នាក់ឆ្លើយបំភ្លឺ ឬហាមឆ្លើយបំភ្លឺចំពោះមុខអង្គប្រជុំផ្សះផ្សា ឬសវនាការ ហើយមានសិទ្ធិបណ្តេញឱ្យចេញពីបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការ ចំពោះជនណា ឬជនទាំងឡាយណាដែលមិនគោរពបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬសវនាការដោះស្រាយពាក្យបណ្តឹង ដូចមានចែងក្នុងឧបសម្ព័ន្ធទី៣ ស្តីពីបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬសវនាការដោះស្រាយពាក្យបណ្តឹង។

### ២.២ សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប

គ.ជ.ប ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប អាចបញ្ចូលរឿងក្តី ក្នុងករណីដែលមានពាក្យបណ្តឹងច្រើន ប៉ុន្តែកម្មវត្ថុនៃពាក្យបណ្តឹងតែមួយ អ្នកប្រព្រឹត្តល្មើសជារូបវន្តបុគ្គលតែម្នាក់ ឬនីតិបុគ្គលតែមួយ ហើយអ្នកប្តឹងជារូបវន្តបុគ្គលតែម្នាក់ ឬនីតិបុគ្គលតែមួយ ទោះទីកន្លែងប្រព្រឹត្តល្មើសមាននៅទូទាំងប្រទេសក៏ដោយ។ ប៉ុន្តែក្រោយពេលដែលក្រុមប្រឹក្សាជំនុំជម្រះចេញសេចក្តីសម្រេចជាស្ថាពរហើយ អ្នកប្រព្រឹត្តល្មើសមិនរាងចាល ដោយនៅតែប្រព្រឹត្តល្មើសដដែលបន្តទៀត ហើយបើមានពាក្យបណ្តឹងថ្មីទៀតនោះ គ.ជ.ប នឹងត្រូវលើកយកមកដោះស្រាយ ដោយចាត់ទុកជាករណីថ្មីទៀត។

ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប មានសិទ្ធិអំណាចកោះហៅគូភាគី និងសាក្សីឱ្យចូលខ្លួនមកបំភ្លឺក្នុងសវនាការ។

ក្នុងពេលសវនាការ ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអនុញ្ញាតឱ្យជនណាម្នាក់ឆ្លើយបំភ្លឺ ឬហាមឆ្លើយបំភ្លឺចំពោះមុខសវនាការ ហើយមានសិទ្ធិបណ្តេញឱ្យចេញពីបន្ទប់សវនាការ ចំពោះជនណា ឬជនទាំងឡាយណាដែលមិនគោរពបទបញ្ជាផ្ទៃក្នុងពេលបើកសវនាការ ដូចមានចែងក្នុងឧបសម្ព័ន្ធទី៣ ស្តីពីបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬសវនាការដោះស្រាយពាក្យបណ្តឹង។

# ផ្នែកទី ២
# សិទ្ធិ និងភារកិច្ចរបស់ដើមបណ្ដឹង ចុងចម្លើយ មេធាវី ឬតំណាង និងសាក្សី

## ១. សិទ្ធិ និងភារកិច្ចរបស់គូភាគី

ក្នុងករណីគូភាគីមានមេធាវី ឬតំណាង ដើម្បីធ្វើជាតំណាង ឬសាក្សី ឬអ្នកដែលពាក់ព័ន្ធនឹងពាក្យបណ្ដឹង ដែលត្រូវចូលរួមបំភ្លឺក្នុងសវនាការនោះត្រូវសុំការអនុញ្ញាតជាមុនពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ មុនពេលបើកសវនាការ។ ចំពោះការប្រជុំផ្សះផ្សា គូភាគីអាចមកចូលរួមដោយផ្ទាល់ ឬចាត់តំណាងដែលត្រូវបានប្រគល់សិទ្ធិ តែមិនតម្រូវឱ្យមានសាក្សីទេ។

គូភាគីត្រូវធ្វើលិខិតប្រគល់សិទ្ធិជូនមេធាវី ឬតំណាង ដោយមានចុះហត្ថលេខា ឬផ្ដិតមេដៃ និងត្រូវមានការយល់ព្រមចុះហត្ថលេខា និងបោះត្រាពីមេធាវី ឬស្នាមមេដៃនៃតំណាងនោះ (**តំណាងត្រូវតែជានីតិជន**[៣])។

លិខិតប្រគល់សិទ្ធិត្រូវបញ្ជាក់ច្បាស់ពីសិទ្ធិរបស់មេធាវី ឬតំណាង ហើយត្រូវដាក់ជូនក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ តាមរយៈលេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ យ៉ាងតិច ២ (ពីរ) ម៉ោងមុនពេលបើកការប្រជុំផ្សះផ្សា ឬបើកសវនាការ។

ដើមបណ្ដឹង និងចុងចម្លើយមិនតម្រូវឱ្យធ្វើសម្បថទេ។

មុនពេលក្រុមប្រឹក្សាជំនុំជម្រះថយទៅពិភាក្សាពិចារណា គូភាគីអាចត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្ដីសន្និដ្ឋានចុងក្រោយ ឬជូនឯកសារទាំងឡាយដែលខ្លួនយល់ថាមានប្រយោជន៍ដល់ខ្លួន ជូនទៅក្រុមប្រឹក្សាជំនុំជម្រះដើម្បីពិចារណា។

គូភាគីមានសិទ្ធិប្ដឹងតវ៉ាចំពោះសេចក្ដីសម្រេចរបស់ គជ.ខប ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គជ.ខប តាមការកំណត់ក្នុង ច.ប.ក និង ប.ន.ក ។

## ២. សិទ្ធិ និងភារកិច្ចរបស់ដើមបណ្ដឹង

ដើមបណ្ដឹងអាចដកពាក្យបណ្ដឹងទាំងមូល ឬមួយផ្នែកបានរហូតដល់ពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ គជ.ខប បញ្ចប់កំណត់ហេតុប្រជុំផ្សះផ្សា ឬរហូតដល់ពេលដែលក្រុមប្រឹក្សាជំនុំជម្រះនៃ គជ.ខប ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ថយទៅពិភាក្សាពិចារណា។ ការដកពាក្យបណ្ដឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរជូនទៅ គជ.ខប ឬ គ.ជ.ប លើកលែងតែនៅពេលកំពុងប្រជុំផ្សះផ្សា ឬកំពុងសវនាការនោះការដកពាក្យបណ្ដឹងអាចធ្វើឡើងដោយផ្ទាល់មាត់បាន។

---

[៣] ជនដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ

ប្រសិនបើដើមបណ្តឹងដកពាក្យបណ្តឹង ធ្វើឡើងមុនពេលដំណើរការប្រជុំផ្សះផ្សា ឬសវនាការ គធ.ខប ឬ គ.ជ.ប ត្រូវសម្រេចលើកពាក្យបណ្តឹងនោះចោល ហើយត្រូវជូនដំណឹងទៅភាគីចុងចម្លើយ។

ប្រសិនបើដើមបណ្តឹងដកពាក្យបណ្តឹង ធ្វើឡើងនៅពេលកំពុងប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំផ្សះផ្សាត្រូវកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សាថា ភាគីដើមបណ្តឹងដកពាក្យបណ្តឹង ហើយពាក្យបណ្តឹងនោះត្រូវបានលើកចោលតាមការស្នើសុំ។

ប្រសិនបើដើមបណ្តឹងដកពាក្យបណ្តឹង ធ្វើឡើងនៅពេលកំពុងសវនាការ ក្រុមប្រឹក្សាជំនុំជម្រះត្រូវសម្រេចលើកពាក្យបណ្តឹងចោល ដោយចេញ ទ.១២០៣។

ដើមបណ្តឹងអាចរាយការណ៍ជាលាយលក្ខណ៍អក្សរ អំពីបញ្ហាដែលកើតមានឡើងដោយខ្លួនឯង ឬតាមរយៈមេធាវី ឬតំណាងដែលបានទទួលសិទ្ធិ ហើយត្រូវបានអនុញ្ញាតឱ្យបង្ហាញឯកសារភស្តុតាង ឬសាក្សី ដើម្បីជាសំអាងក្នុងរឿងក្តីរបស់ខ្លួន។

នៅក្នុងនីតិវិធីសវនាការតទល់ ដោយមានការយល់ព្រមពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ ដើមបណ្តឹងអាចតាំងសំណួរទៅចុងចម្លើយ ឬសាក្សីរបស់ចុងចម្លើយ។ ចុងចម្លើយក៏អាចចោទសំណួរទៅដើមបណ្តឹង ឬសាក្សីរបស់ដើមបណ្តឹង។

ដើមបណ្តឹង ឬ/និងជនរងគ្រោះ មាន**វិសមិតភាព**[៤] រវាងឋានៈជាដើមបណ្តឹង ឬជនរងគ្រោះ និងឋានៈជាសាក្សី។ ដើមបណ្តឹង ឬ/និងជនរងគ្រោះមិនអនុញ្ញាតឱ្យផ្តល់ចម្លើយក្នុងឋានៈជាសាក្សីបានទេ។

## ៣. សិទ្ធិ និងភារកិច្ចរបស់ចុងចម្លើយ

ចុងចម្លើយអាចធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីបញ្ហានានា ដែលទាក់ទងនឹងពាក្យបណ្តឹងដោយខ្លួនឯង ឬតាមរយៈមេធាវី ឬតំណាងដែលបានទទួលសិទ្ធិ ហើយត្រូវបង្ហាញឯកសារភស្តុតាង ឬសាក្សី ដើម្បីសំអាងការពាររឿងក្តីរបស់ខ្លួន។

ចុងចម្លើយអាចបង្ហាញភស្តុតាងជាទឡ្ហីករណ៍ចុងក្រោយរបស់ខ្លួន ដោយខ្លួនឯង ឬតាមរយៈមេធាវី ឬតំណាង ដើម្បីឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់ដើមបណ្តឹង។

---

[៤] ភាពដែលមិនអាចមាន ឬប្រកបកិច្ចការចូលគ្នាបាន

## ៤. សិទ្ធិ និងភារកិច្ចរបស់មេធាវី ឬតំណាង

មេធាវី ឬតំណាងដែលបានទទួលសិទ្ធិពីដើមបណ្ដឹង ឬចុងចម្លើយ មិនអាចធ្វើការប្រគល់សិទ្ធិបន្តទៅមេធាវី ឬតំណាងដទៃទៀត ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអ្នកប្រគល់សិទ្ធិដំបូងបានឡើយ។

ដើមបណ្ដឹង ឬចុងចម្លើយ ឬមេធាវី ឬតំណាងរបស់គូភាគី អាចស្នើសុំឱ្យ គជ.ខប ឬ គ.ជ.ប ថតចម្លងសំណុំរឿងពាក់ព័ន្ធឱ្យខ្លួន ដោយត្រូវបង់ប្រាក់ត្រឹមថ្លៃផលិតប៉ុណ្ណោះ។ ការថតចម្លងត្រូវធ្វើដោយមន្ត្រីបោះឆ្នោតដែលត្រូវបានចាត់តាំង។

## ៥. សិទ្ធិ និងភារកិច្ចរបស់សាក្សី

សាក្សីត្រូវធ្វើសម្បថជាមុន ហើយត្រូវឆ្លើយបំភ្លឺជូនក្រុមប្រឹក្សាជំនុំជម្រះនៅចំពោះមុខក្រុមប្រឹក្សាជំនុំជម្រះ និងសន្យាទទួលខុសត្រូវនៅចំពោះមុខច្បាប់ អំពីការផ្តន្ទាទោសចំពោះការផ្តល់សក្ខីកម្មភូតកុហក ប្រសិនបើខ្លួនឆ្លើយបំផ្លើសការពិត (ខ្លឹមសារសម្បថមានក្នុងឧបសម្ព័ន្ធទី៤ ស្តីពីនីតិវិធី និងខ្លឹមសារនៃសម្បថ)។

សាក្សីមានសិទ្ធិឆ្លើយបំភ្លឺនូវការពិតដែលខ្លួនបានឃើញ បានដឹង បានឮ និងបានចាំ ដោយគ្មានការបង្ខិតបង្ខំពីបុគ្គលណាមួយឡើយ។

សាក្សីដើមបណ្តឹង និងសាក្សីចុងចម្លើយ ត្រូវស្ថិតនៅក្នុងបន្ទប់ផ្សេងគ្នា រង់ចាំការអញ្ជើញឱ្យចូលមកបំភ្លឺដោយក្រុមប្រឹក្សាជំនុំជម្រះ ហើយមិនត្រូវបានអនុញ្ញាតឱ្យទាក់ទងគ្នាទោះតាមមធ្យោបាយណាក៏ដោយ ក្នុងថ្ងៃដែលបានអញ្ជើញឱ្យចូលរួមសវនាការ។

សាក្សីពុំត្រូវបានអនុញ្ញាតឱ្យឃើញ ឬស្តាប់ការសួរដេញដោលនៅក្នុងបន្ទប់សវនាការឡើយ លើកលែងតែមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ។

# ផ្នែកទី៣
# នីតិវិធីប្រជុំផ្សះផ្សា ឬសវនាការ

ដំណើរការប្រជុំផ្សះផ្សា ឬសវនាការត្រូវដឹកនាំ និងចាត់ចែងដោយប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ។ ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអនុញ្ញាតឱ្យជនណាម្នាក់ឆ្លើយបំភ្លឺ ឬហាមឆ្លើយបំភ្លឺចំពោះមុខអង្គប្រជុំផ្សះផ្សា ឬសវនាការ ហើយមានសិទ្ធិបណ្តេញឱ្យចេញពីបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការ ចំពោះជនណា ឬជនទាំងឡាយណាដែលមិនគោរពបទបញ្ជាផ្ទៃក្នុងពេលប្រជុំផ្សះផ្សា ឬសវនាការដោះស្រាយពាក្យបណ្តឹង (ដូចមានចែងក្នុងឧបសម្ព័ន្ធទី៣ បទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬសវនាការដោះស្រាយពាក្យបណ្តឹង)។

## ១. ប្រភេទសវនាការ

ក្រុមប្រឹក្សាជំនុំជម្រះអាចធ្វើសវនាការសង្ខេប ឬសវនាការតទល់ ឬសវនាការសួរដេញដោល។

**សវនាការសង្ខេប** ជាសវនាការដែលគ្មានទម្រង់ការច្រើន។ ក្រុមប្រឹក្សាជំនុំជម្រះគ្រាន់តែធ្វើសេចក្តីសម្រេចមួយឆ្លើយតប នៅពេលយល់ឃើញថាមានតែចំណោទខាងអង្គច្បាប់ប៉ុណ្ណោះ ហើយគ្មានចំណោទខាងអង្គហេតុ។

**សវនាការតទល់** ជាសវនាការដែលបើកឱ្យភាគីទំនាស់ជជែកតទល់គ្នាអំពីរឿងពាក្យបណ្តឹង។ ភាគីទំនាស់កំណត់អំពីអង្គហេតុ និងត្រូវប្រមូលភស្តុតាង ដើម្បីដាក់ជូនសវនាការ។

**សវនាការសួរដេញដោល** ជាសវនាការដែលក្រុមប្រឹក្សាជំនុំជម្រះមានតួនាទីយ៉ាងសំខាន់ក្នុងការសួរដេញដោលរកហេតុផលក្នុងរឿងក្តី។ ក្នុងសវនាការប្រភេទនេះ ទាំងក្រុមប្រឹក្សាជំនុំជម្រះ ទាំងគូក្តីជាអ្នកទទួលខុសត្រូវក្នុងការប្រមែប្រមូលភស្តុតាងផ្សេងៗដែលត្រូវដាក់បង្ហាញក្នុងសវនាការ ប៉ុន្តែក្រុមប្រឹក្សាជំនុំជម្រះមានតួនាទីទទួលខុសត្រូវសំខាន់ជាអ្នកតាំងសំណួរដល់សាក្សី ចំណែកឯគូក្តីមានតួនាទីបន្ទាប់បន្សំតែប៉ុណ្ណោះ។ ការចោទសួរដេញដោលនេះអាចធ្វើទៅបានដោយមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ។

## ២. ភាសាដែលត្រូវប្រើក្នុងការប្រជុំផ្សះផ្សា ឬសវនាការ

ភាសាដែលត្រូវប្រើក្នុងការប្រជុំផ្សះផ្សា ឬសវនាការ គឺភាសាខ្មែរ។

ភាគីដែលមិនអាចយល់ភាសាខ្មែរ អាចរកអ្នកបកប្រែភាសាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ដោយខ្លួនឯង។

## ៣. ពេលវេលាដោះស្រាយពាក្យបណ្ដឹង

ការប្រជុំផ្សះផ្សា ឬសវនាការ អាចធ្វើជារៀងរាល់ថ្ងៃ ព្រឹកចាប់ពីម៉ោង ៨:០០ (ប្រាំបី) ដល់ម៉ោង ១១:៣០ (ដប់មួយ សាមសិប) នាទី និងរសៀលចាប់ពីម៉ោង ១៤:០០ (ដប់បួន) ដល់ម៉ោង ១៧:៣០ (ដប់ប្រាំពីរ សាមសិប) នាទី។ ក្នុងករណីចាំបាច់ ការប្រជុំផ្សះផ្សា ឬសវនាការអាចបន្តធ្វើទៅតាមស្ថានភាពជាក់ស្ដែង ឬធ្វើនៅម៉ោងផ្សេងក្រៅពីការកំណត់នេះ។

ក្នុងករណីដែលថ្ងៃកំណត់ដោះស្រាយពាក្យបណ្ដឹង និងសម្រេចលើពាក្យបណ្ដឹង ចំថ្ងៃបុណ្យជាផ្លូវការ ការប្រជុំផ្សះផ្សា ឬសវនាការត្រូវលើកទៅថ្ងៃបន្ទាប់។

ក្នុងកម្មវិធីមួយពេលនៃការបើកប្រជុំផ្សះផ្សា ឬបើកសវនាការលើពាក្យបណ្ដឹង អាចកំណត់ធ្វើការប្រជុំផ្សះផ្សា ឬសវនាការច្រើនករណីនៃពាក្យបណ្ដឹងបាន។

## ៤. ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកសវនាការ

### ៤.១ ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកសវនាការនៅ គធ.ខប

គធ.ខប ត្រូវពិភាក្សាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីកំណត់ប្រតិទិនសម្រាប់ប្រជុំផ្សះផ្សា ឬ/និងបើកសវនាការនៅថ្នាក់របស់ខ្លួនទៅតាមករណីនៃពាក្យបណ្ដឹង និងទៅតាមរយៈពេលកំណត់ដូចមានចែងនៅក្នុង ច.ប.ក ច.ប.ត.រ ច.វ.ច.ប និង ប.ន.ក ។

គធ.ខប ត្រូវធានាប្រគល់លិខិតអញ្ជើញអំពីការបើកប្រជុំផ្សះផ្សា ឬបើកសវនាការដល់គូភាគីឱ្យបានទាន់ពេលវេលាយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោង មុនពេលការប្រជុំផ្សះផ្សា ហើយត្រូវជូនដំណឹងភ្លាមនៅនឹងកន្លែងផ្សះផ្សា (ក្នុងករណីផ្សះផ្សាមិនសះជា) ទៅគូភាគីពាក់ព័ន្ធឱ្យបានដឹងពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងបើកសវនាការតែម្ដង។

### ៤.២ ការជូនដំណឹងបើកសវនាការនៅ គ.ជ.ប

គ.ជ.ប ត្រូវកំណត់ប្រតិទិនសម្រាប់ដោះស្រាយពាក្យបណ្ដឹង ឬ/និងបើកសវនាការនៅថ្នាក់ គ.ជ.ប ទៅតាមករណីនៃពាក្យបណ្ដឹង និងទៅតាមរយៈពេលកំណត់ដូចមានចែងនៅក្នុង ច.ប.ក ច.ប.ត.រ ច.វ.ច.ប និង ប.ន.ក ។

នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវធានាប្រគល់លិខិតអញ្ជើញ អំពីការបើកសវនាការដល់គូភាគីឱ្យបានទាន់ពេលវេលាយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោង មុនពេលបើកសវនាការ។

## ៥. ភារកិច្ចរបស់លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ

លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ មានភារកិច្ចដូចខាងក្រោម ៖

- បិទផ្សាយ និងអានបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬសវនាការឱ្យអ្នកចូលរួមបានជ្រាប
- នាំសាក្សីទៅស្បថ (ករណីសវនាការ)
- ប្រាប់ទៅអ្នកចូលរួមទាំងអស់ឱ្យក្រោកឈរនៅពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះអញ្ជើញមកដល់
- ពិនិត្យ និងស្រង់វត្តមាន អវត្តមានដើមបណ្តឹង ចុងចម្លើយ មេធាវី ឬតំណាង ដែលត្រូវចូលរួមប្រជុំផ្សះផ្សា ឬសវនាការ លើកលែងតែសវនាការដែលត្រូវស្រង់វត្តមានសាក្សី
- រាយការណ៍អំពីវត្តមាន ឬអវត្តមានភាគីពាក់ព័ន្ធជូនក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ
- ត្រូវសរសេរដោយដៃ ឬដោយកុំព្យូទ័រនូវកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុសវនាការក្នុងពេលប្រជុំផ្សះផ្សា ឬសវនាការ។ ការកត់ត្រាកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុសវនាការមិនត្រូវទុកឱ្យមានចន្លោះបន្ទាត់ទំនេរទេ។ ពាក្យឆូតលុបចោល និងពាក្យសរសេរយោងត្រូវមានសេចក្តីបញ្ជាក់ និងមានហត្ថលេខារបស់លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការសវនាការ ឬប្រធានគណៈលេខាធិការសវនាការ ប្រធាន និងសមាជិកក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ និងភាគីពាក់ព័ន្ធ
- អានឯកសារផ្សេងៗដែលពាក់ព័ន្ធតាមការបង្គាប់ពីប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- រៀបចំ ទ.១២០៣ រួចចុះហត្ថលេខា ហើយដាក់ជូនប្រធានក្រុមប្រឹក្សាជំនុំជម្រះចុះហត្ថលេខា ឈ្មោះ បោះត្រា និងចុះកាលបរិច្ឆេទ
- អញ្ជើញភាគីផ្តិតមេដៃលើកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុសវនាការក្នុងករណីភាគីណាមួយមិនព្រមផ្តិតមេដៃ លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការសវនាការ ឬប្រធានគណៈលេខាធិការសវនាការត្រូវចុះនិទ្ទេសអំពីការមិនព្រមផ្តិតមេដៃលើកំណត់ហេតុនោះ។

## ៦. ការរៀបចំកន្លែង និងរបៀបរបបការងាររបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬ ក្រុមប្រឹក្សាជំនុំជម្រះ

នៅថ្ងៃប្រជុំផ្សះផ្សា ឬសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ ត្រូវអញ្ជើញចូលអង្គុយតាមទីកន្លែងដែលបានរៀបចំទុក។ ប្រធានអង្គុយនៅកណ្ដាល សមាជិកអង្គុយអមសងខាង និងលេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ ត្រូវអង្គុយនៅនឹងតុដែលនៅខាងឆ្វេងដៃ ឬស្ដាំដៃ នៃក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ។

ក្រោយពីបានអញ្ជើញអង្គុយតាមទីកន្លែងរួចមក ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវ ៖

ទី១. ប្រកាសសមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ។

ទី២. ប្រកាសសំណុំរឿង និងប្រកាសបើកការប្រជុំផ្សះផ្សា ឬសវនាការ។

ទី៣. បង្គាប់ឱ្យលេខាធិការសវនាការ ឬប្រធានគណៈលេខាធិការសវនាការ រាយការណ៍អំពីវត្តមានដើមបណ្ដឹង ចុងចម្លើយ និងសាក្សី (ករណីសវនាការ)។

មុននឹងចាប់ផ្ដើមផ្សះផ្សា ឬសួរដេញដោល ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬ ប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវសួរទៅដើមបណ្ដឹងថា **តើលោក ឬលោកស្រីនៅតែបន្តប្ដឹងដូចមានចែងក្នុងកម្មវត្ថុនៃពាក្យបណ្ដឹង ឬមានការកែប្រែឬទេ ?** ប្រសិនបើ ៖

- ដើមបណ្ដឹងឆ្លើយថា ខ្លួនដកពាក្យបណ្ដឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវបង្គាប់លេខាធិការអង្គប្រជុំផ្សះផ្សា ឬ លេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ ឱ្យកត់ត្រាក្នុង កំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុសវនាការហើយឱ្យដើមបណ្ដឹង ផ្តិតមេដៃលើកំណត់ហេតុនោះ។ បន្ទាប់មកក្រុមប្រឹក្សាប្រជុំផ្សះផ្សាអាច ផ្សះផ្សារឿងក្ដីផ្សេងទៀត (ប្រសិនបើមាន) ឬក្រុមប្រឹក្សាជំនុំជម្រះអាចថយ ទៅពិភាក្សាពិចារណា ឬបន្តទៅសវនាការ រឿងក្ដីផ្សេងទៀត (ប្រសិនបើមាន)
- ដើមបណ្ដឹងនៅតែបន្តប្ដឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុម ប្រឹក្សាជំនុំជម្រះត្រូវ ចាប់ផ្ដើមដំណើរការប្រជុំផ្សះផ្សា ឬសវនាការ។

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវសួរដេញដោលទៅដើមបណ្ដឹងមុនរួចត្រូវសួរទៅចុងចម្លើយ។ បន្ទាប់មកប្រធានត្រូវសួរសាក្សីដើមបណ្ដឹង សាក្សីចុងចម្លើយ និងអ្នកពាក់ព័ន្ធ រួចឱ្យភាគីដើមបណ្ដឹង និងភាគីចុងចម្លើយធ្វើសំណូមពរចុងក្រោយ។

ប្រសិនបើមានមេធាវីការពារក្ដី ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវផ្ដល់ពេលវេលាឱ្យមេធាវីនិយាយការពារកូនក្ដី សួរភាគី (ប្រសិនបើមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ) និងធ្វើសេចក្ដីសន្និដ្ឋានចុងក្រោយ មុនក្រុមប្រឹក្សាជំនុំជម្រះថយទៅពិភាក្សាពិចារណា។

ក្នុងពេលដំណើរការប្រជុំផ្សះផ្សា ឬសវនាការ ប្រសិនបើដើមបណ្ដឹងសុំដកពាក្យបណ្ដឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវបញ្ចប់ការផ្សះផ្សា ឬការសួរដេញដោលនោះភ្លាម រួចត្រូវអនុវត្តដូចគ្នានឹងករណីដើមបណ្ដឹងដកពាក្យបណ្ដឹង ពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះសួរពេលដំបូងដែរ។

ក្រោយពីបានដំណើរការសវនាការតាមលំដាប់លំដោយរួចហើយ ក្រុមប្រឹក្សាជំនុំជម្រះត្រូវថយទៅពិភាក្សាពិចារណានៅក្នុងបន្ទប់សម្ងាត់។ រាល់ការសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះត្រូវផ្អែកលើអង្គហេតុ និងអង្គច្បាប់។

ក្រុមប្រឹក្សាជំនុំជម្រះ ត្រូវប្រកាសសេចក្ដីសម្រេចភ្លាមបន្ទាប់ពីពិភាក្សាគ្នារួចរាល់។ បញ្ញត្តិនេះមិនត្រូវបានយកមកអនុវត្តឡើយ ចំពោះពាក្យបណ្ដឹងដែលមានភាពស្មុគស្មាញខ្លាំង ឬមានកាលៈទេសៈពិសេសផ្សេងទៀត ប៉ុន្តែមិនត្រូវឱ្យហួសរយៈពេលកំណត់នៃការដោះស្រាយពាក្យបណ្ដឹងឡើយ។

ការប្រកាសសេចក្ដីសម្រេច ត្រូវធ្វើឡើងដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះជាអ្នកអានសេចក្ដីសម្រេច ដោយផ្អែកលើច្បាប់ដើមនៃសេចក្ដីសម្រេច។ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ អាចចាត់តាំងសមាជិកក្រុមប្រឹក្សាជំនុំជម្រះណាម្នាក់អានជំនួសបាន។

## ៧. ការបង្ហាញខ្លួននៅពេលប្រជុំផ្សះផ្សា ឬសវនាការ

ប្រសិនបើភាគីដើមបណ្ដឹងបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែភាគីនោះមិនបានមកបង្ហាញខ្លួននៅថ្ងៃប្រជុំផ្សះផ្សាតាមពេលកំណត់ទេនោះ ក្រុមប្រឹក្សាប្រជុំផ្សះផ្សាត្រូវសម្រេចលើកពាក្យបណ្ដឹងចោល ដោយធ្វើលិខិតជូនដំណឹងទៅភាគីដើមបណ្ដឹង។

ប្រសិនបើភាគីដើមបណ្តឹងបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែភាគីនោះមិនបានមកបង្ហាញខ្លួននៅថ្ងៃសវនាការទេ នោះក្រុមប្រឹក្សាជំនុំជម្រះត្រូវសម្រេចកំបាំងមុខដើមបណ្តឹង ប៉ុន្តែចាត់ទុកជាចំពោះមុខ ដោយបញ្ជាក់ពីមូលហេតុលើសេចក្តីសម្រេច។

ប្រសិនបើភាគីដើមបណ្តឹងស្លាប់ នោះក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះនៅតែបន្តនីតិវិធីរបស់ខ្លួនដដែល។

ប្រសិនបើភាគីចុងចម្លើយស្លាប់មុនពេលបើកការប្រជុំផ្សះផ្សា ឬសវនាការក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ ត្រូវលុបពាក្យបណ្តឹងចេញពីបញ្ជីហើយត្រូវជូនដំណឹងទៅភាគីដើមបណ្តឹងឱ្យបានជ្រាប។

ប្រសិនបើភាគីចុងចម្លើយបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែមិនមកបង្ហាញខ្លួននៅថ្ងៃប្រជុំផ្សះផ្សា ឬថ្ងៃសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះនៅតែបន្តនីតិវិធីរបស់ខ្លួនដដែល។

ប្រសិនបើដើមបណ្តឹង ឬចុងចម្លើយមិនបានបង្ហាញខ្លួននាថ្ងៃសវនាការក្រុមប្រឹក្សាជំនុំជម្រះត្រូវចាត់លេខាធិការសវនាការ ឬគណៈលេខាធិការសវនាការព្រមទាំងស្នើសុំកិច្ចសហការពីអាជ្ញាធរឃុំ សង្កាត់អមដំណើរទៅជាមួយ ដើម្បីបញ្ជូន ទ.១២០៣ ទៅជូនដើមបណ្តឹង ឬចុងចម្លើយនៅអាសយដ្ឋានរបស់ដើមបណ្តឹង ឬចុងចម្លើយ ឬទីស្នាក់ការគណបក្សនយោបាយរបស់ដើមបណ្តឹង ឬចុងចម្លើយនោះ។ ប្រសិនបើដើមបណ្តឹង ឬចុងចម្លើយបដិសេធ ដោយមិនទទួលយក ទ.១២០៣ នោះលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ ឬមន្ត្រី គ.ជ.ប ត្រូវចារលើ ទ.១២០៣ នោះ ដោយបញ្ជាក់ឱ្យបានច្បាស់ថា "**អ្នកប្តឹង ឬតំណាង ឬចុងចម្លើយ ឬតំណាងមិនព្រមទទួលយក ទ.១២០៣**" ហើយចុះកាលបរិច្ឆេទ ឈ្មោះ និងហត្ថលេខាព្រមទាំងមានហត្ថលេខារបស់អាជ្ញាធរឃុំ សង្កាត់ដែលអមដំណើរទៅជាមួយដើម្បីបញ្ជាក់ថាភាគីនៃពាក្យបណ្តឹងពិតជាមិនព្រមទទួលយក ទ.១២០៣ រួចបិទ ទ.១២០៣ នោះ នៅមុខលំនៅឋាន ឬទីសំណាក់ ឬទីស្នាក់ការគណបក្សនយោបាយរបស់ភាគីនោះ ហើយចាត់ទុកថាភាគីនៃពាក្យបណ្តឹងបានទទួល ទ.១២០៣រួចហើយ។

## ៨.មធ្យោបាយបង្ហាញភស្តុតាង

មធ្យោបាយបង្ហាញភស្តុតាង ដែលប្រើប្រាស់ក្នុងតុលាការជំនុំជម្រះក្តីក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវយកមកប្រើប្រាស់ក្នុងអង្គប្រជុំផ្សះផ្សា ឬសវនាការនេះ។

ភស្តុតាងអាចបង្ហាញបានតាមគ្រប់មធ្យោបាយ និងត្រូវគោរព ច.ប.ក ច.ប.ត.រ ច.វ.ច.ប និង ប.ន.ក ។

ជនណាបានប្រព្រឹត្តអំពើក្លែងលិខិត ឬឯកសារ ដោយក្លែងហត្ថលេខា ឬស្នាមមេដៃ ឬតាមមធ្យោបាយណាក៏ដោយ និងជនណាដែលបានប្រើប្រាស់នូវលិខិត ឬឯកសារក្លែងនោះ ជននោះនឹងត្រូវមានទោសតាមច្បាប់ជាធរមាន។

## ៩. ការបំពេញ និងប្រើប្រាស់ ទ.១២០៣

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវធ្វើឡើងដោយផ្អែកតាមកំណត់ហេតុសវនាការ ហើយត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ។ សេចក្តីសម្រេចនេះ ត្រូវស្រង់ដាក់ក្នុង ទ.១២០៣ ហើយត្រូវចុះហត្ថលេខាដោយលេខាធិការសវនាការ ឬប្រធានគណៈលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយត្រូវធ្វើឡើងតាមចំនួន និងកម្មវត្ថុនៃពាក្យបណ្តឹង ឬចំនួនផ្សេងទៀតតាមការចាំបាច់។ ទ.១២០៣ របស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវធ្វើឡើងដោយផ្អែកតាមលទ្ធផលនៃការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ។

ការបំពេញ ទ.១២០៣ នៅ គធ.ខប ត្រូវធ្វើជា ៣ (បី) ច្បាប់ សម្រាប់ពាក្យបណ្តឹងតវ៉ា ឬ ៤ (បួន) ច្បាប់ សម្រាប់ពាក្យបណ្តឹងជំទាស់ ដើម្បី ៖

- ជូន ឬផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ជាបន្ទាន់
- ជូន ឬផ្ញើជូនអ្នកដែលត្រូវគេប្តឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ (ចំពោះពាក្យបណ្តឹងជំទាស់) ជាបន្ទាន់
- ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និង
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ការបំពេញ ទ.១២០៣ នៅ គ.ជ.ប ត្រូវធ្វើជា ៣ (បី) ច្បាប់ សម្រាប់ពាក្យបណ្តឹងតវ៉ា ឬ ៤ (បួន) ច្បាប់ សម្រាប់ពាក្យបណ្តឹងជំទាស់ ដើម្បី ៖

- ជូន ឬផ្ញើជូនអ្នកប្តឹង ឬតំណាង ១ ច្បាប់ ជាបន្ទាន់
- ជូន ឬផ្ញើជូនអ្នកដែលត្រូវគេប្តឹងជំទាស់ ឬតំណាង ១ ច្បាប់ (ចំពោះពាក្យបណ្តឹងជំទាស់) ជាបន្ទាន់
- ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និង
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

គ.ជ.ប ត្រូវចាត់តាំងមន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប ១ (មួយ) រូប ឱ្យទទួលបន្ទុកជាមន្ត្រីប្រគល់សម្រង់សេចក្តីសម្រេច។ ទ.១២០៣ ត្រូវប្រគល់ជូនទៅភាគីនៃពាក្យបណ្តឹងភ្លាមៗ បន្ទាប់ពី គ.ជ.ប បញ្ចប់សវនាការ ហើយការប្រគល់ ទទួល ទ.១២០៣ នេះ ត្រូវមានកំណត់ហេតុដែលបញ្ជាក់ពីពេលវេលា និងកាលបរិច្ឆេទនៃការប្រគល់ ទទួលឱ្យបានច្បាស់លាស់។ កំណត់ហេតុនេះ ត្រូវចុះហត្ថលេខាដោយមន្ត្រីទទួលបន្ទុកប្រគល់សម្រង់សេចក្តីសម្រេចនៃ គ.ជ.ប និងហត្ថលេខារបស់អ្នកទទួលជាក់ស្តែង។ ក្នុងករណី ៖

- ភាគីនៃពាក្យបណ្តឹងណាមួយបដិសេធមិនព្រមទទួលយក ទ.១២០៣ មន្ត្រីទទួលបន្ទុកប្រគល់សម្រង់សេចក្តីសម្រេចនៃ គ.ជ.ប ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមទទួលយកឱ្យបានច្បាស់លាស់
- ភាគីនៃពាក្យបណ្តឹងជាភ្នាក់ងារគណបក្សនយោបាយ ឬតំណាងគណបក្សនយោបាយ បដិសេធ មិនព្រមទទួលយក ទ.១២០៣ មន្ត្រីទទួលបន្ទុកប្រគល់សម្រង់សេចក្តីសម្រេចនៃ គ.ជ.ប ត្រូវបញ្ជូន ទ.១២០៣ ដោយមានដីការអមទៅទីស្នាក់ការគណបក្សនយោបាយរបស់ភាគីនោះ។ កាលបរិច្ឆេទនៃការទទួលដីការអម ត្រូវចាត់ទុកជាកាលបរិច្ឆេទទទួល ទ.១២០៣។

## ១០. ទម្រង់បែបបទផ្សេងៗទៀត សម្រាប់ការប្រជុំផ្សះផ្សា និងសវនាការ

គធ.ឃប ឬ គ.ជ.ប មានទម្រង់បែបបទផ្សេងៗទៀត សម្រាប់ប្រើប្រាស់ក្នុងការប្រជុំផ្សះផ្សា ឬសវនាការ មានជាអាទិ៍ លិខិតអញ្ជើញឱ្យចូលរួមប្រជុំផ្សះផ្សា ឬសវនាការ កំណត់ហេតុសាកសួរ កំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុសវនាការ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ឃប និង គ.ជ.ប ។

លិខិតអញ្ជើញឱ្យចូលរួមប្រជុំផ្សះផ្សា ឬសវនាការ ត្រូវបំពេញតាមចំនួនជាក់ស្តែងនៃអ្នកពាក់ព័ន្ធដែលត្រូវបានអញ្ជើញឱ្យចូលរួមប្រជុំផ្សះផ្សា ឬសវនាការរួចប្រគល់ជូនភាគីពាក់ព័ន្ធ ១ (មួយ) ច្បាប់ៗ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

កំណត់ហេតុសាកសួរ អាចធ្វើឡើងដោយដៃ ឬដោយវាយកុំព្យូទ័រ។

កំណត់ហេតុប្រជុំផ្សះផ្សាត្រូវបំពេញដោយលេខាធិការអង្គប្រជុំផ្សះផ្សា ចំនួន ១ (មួយ) ច្បាប់ ដោយត្រូវកត់ត្រានូវរាល់ចម្លើយដាក់បន្ទុក ឬចម្លើយដោះសាររបស់ភាគីពាក់ព័ន្ធនឹងពាក្យបណ្តឹង និងលទ្ធផលនៃការផ្សះផ្សា។

កំណត់ហេតុសវនាការត្រូវបំពេញដោយលេខាធិការសវនាការ ឬគណៈ-លេខាធិការសវនាការ ចំនួន ១ (មួយ) ច្បាប់ ដោយត្រូវកត់ត្រានូវរាល់ចម្លើយដាក់បន្ទុក និងចម្លើយដោះសាររបស់ភាគីពាក់ព័ន្ធនឹងពាក្យបណ្តឹង ព្រមទាំងការយល់ឃើញ និងការសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប និងក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវសរសេរចំណុច (១) រដ្ឋធម្មនុញ្ញ ច្បាប់ និងបទបញ្ជាពាក់ព័ន្ធនឹងការបោះឆ្នោត ពាក្យបណ្តឹង លិខិតប្រគល់សិទ្ធិ ឬ/និងកំណត់ហេតុ ឬ/និងរបាយការណ៍ផ្សេងៗ (២) ការយល់ឃើញ និងការសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ។ ច្បាប់ចតចម្លងនៃសេចក្តីសម្រេចនេះ អាចផ្តល់ជូនគូភាគីបានប្រសិនបើមានការស្នើសុំ។

# ឧបសម្ព័ន្ធទី ១
## ទម្រង់បែបបទពាក្យបណ្តឹង (ឧ.១២០២)

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

# ពាក្យបណ្តឹង (ឧ.១២០២)

**I. សម្រាប់អ្នកប្តឹង**

១. អត្តសញ្ញាណអ្នកប្តឹង

- ឈ្មោះអ្នកប្តឹង ៖ ........................ ភេទ ........ ថ្ងៃខែឆ្នាំកំណើត ........
- ទីលំនៅបច្ចុប្បន្ន ៖ ផ្ទះលេខ ........ ផ្លូវ ........ ភូមិ ........ ឃុំ សង្កាត់ ........
  ក្រុង ស្រុក ខណ្ឌ ........................ រាជធានី ខេត្ត ........
- តួនាទី/មុខងារ ៖ ☐ប្រជាពលរដ្ឋ ☐ភ្នាក់ងារគណបក្សនយោបាយ ........
  ☐ផ្សេងៗ ........................ ទូរស័ព្ទទាក់ទង ........

២. លក្ខណៈសម្គាល់នៃទីកន្លែងពាក់ព័ន្ធនឹងបណ្តឹង

| រាជធានី ខេត្ត | | | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ | | | | លេខកូដការិយាល័យ | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| លេខកូដ | | | | លេខកូដ | | | | | | | |

៣. កម្មវត្ថុនៃបណ្តឹង ៖ ..................................................
..................................................
..................................................
..................................................

៤. មូលហេតុនៃការប្តឹង ៖ ..................................................
..................................................
..................................................
..................................................
..................................................
..................................................
..................................................
..................................................(ករណីត្រូវការបន្ថែមសូមសរសេរនៅខាងខ្នង)

៥. កាលបរិច្ឆេទ ៖ ........../........../..........

៦. ហត្ថលេខា ឬស្នាមមេដៃអ្នកប្តឹង (ប្រសិនបើអ្នកជាតំណាង ត្រូវមានលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរភ្ជាប់មកជាមួយ)

**II. សម្រាប់មន្ត្រីទទួលបន្ទុកការងារបោះឆ្នោត**

ថ្ងៃ ........ ខែ ........ ឆ្នាំ ........ ព.ស. ........
........................ ថ្ងៃទី ........ ខែ ........ ឆ្នាំ ........

| លេខពាក្យបណ្តឹង | កាលបរិច្ឆេទទទួលពាក្យបណ្តឹង | កាលបរិច្ឆេទប្រជុំសម្រេច ឬបើកសវនាការ |
|---|---|---|
| | ........../........../.......... | |
| | ម៉ោង........ព្រឹក☐, សៀល☐ | ........../........../.......... |

**ហត្ថលេខា និងត្រា**

ទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញដោយអ្នកប្តឹងតវ៉ា ឬប្តឹងជំទាស់

# ឧបសម្ព័ន្ធទី ២

## ទម្រង់បែបបទសម្រង់សេចក្ដីសម្រេច (ឧ.១២០៣)

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

### សម្រង់សេចក្ដីសម្រេច (ឧ.១២០៣)

១. លេខបណ្ដឹង/សំណុំរឿង និងសេចក្ដីសម្រេច

- បណ្ដឹង/សំណុំរឿងលេខ.................. ចុះថ្ងៃទី........ ខែ.......... ឆ្នាំ............ វេលាម៉ោង............
- សេចក្ដីសម្រេចលេខ............................ចុះថ្ងៃទី............... ខែ............... ឆ្នាំ............

២. អត្តសញ្ញាណអ្នកប្ដឹង

- ឈ្មោះអ្នកប្ដឹង..............................................ភេទ............ ថ្ងៃខែឆ្នាំកំណើត............
- ទីលំនៅបច្ចុប្បន្នផ្ទះលេខ............ ផ្លូវ............ ភូមិ............ ឃុំ សង្កាត់............
  ក្រុង ស្រុក ខណ្ឌ..............................................រាជធានី ខេត្ត............................
- តួនាទី/មុខងារ..................................................................................................

៣. កម្មវត្ថុនៃបណ្ដឹង.........................................................................................

.........................................................................................................................

.........................................................................................................................

៤. លក្ខណៈសម្គាល់នៃទីកន្លែងពាក់ព័ន្ធនឹងបណ្ដឹង

| រាជធានី ខេត្ត | | |
|---|---|---|
| លេខកូដ | | |

| ក្រុង ស្រុក ខណ្ឌ |
|---|
| |

| ឃុំ សង្កាត់ | | | |
|---|---|---|---|
| លេខកូដ | | | |

| លេខកូដការិយាល័យ | | | |
|---|---|---|---|
| | | | |

### សម្រេច

.........................................................................................................................

.........................................................................................................................

.........................................................................................................................

.........................................................................................................................

.........................................................................................................................

.........................................................................................................................

.........................................................................................................................

.........................................................................................................................

បានស្រង់ត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ...................... ខែ.............. ឆ្នាំ.................. ព.ស..............

..................................ថ្ងៃទី.......... ខែ.......... ឆ្នាំ..........

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬអង្គប្រជុំសម្រេច**

**ហត្ថលេខា និងត្រា**

**លេខាធិការសវនាការ ឬអង្គប្រជុំសម្រេច**

**ហត្ថលេខា**

ទម្រង់បែបបទលេខ ១២០៣ សម្រាប់បំពេញដោយក្រុមប្រឹក្សាជំនុំជម្រះ ឬអង្គប្រជុំសម្រេច

# ឧបសម្ព័ន្ធទី ៣
# បទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬសវនាការ ដោះស្រាយពាក្យបណ្ដឹង

ដើម្បីរក្សាសណ្ដាប់ធ្នាប់ របៀបរៀបរយ សុវត្ថិភាព និងសន្តិសុខក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការ ជនគ្រប់រូបដែលមានវត្តមានក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការ ត្រូវគោរព និងអនុវត្តតាមបទបញ្ជាដូចតទៅ ៖

១. ហាមជក់បារីក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការ។

២. ហាមបង្កភាពអនាធិបតេយ្យក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការដូចជា ៖
   - ការដើរឆ្លងកាត់ ឬដើរចេញ ចូលរហោតរហូត ដោយគ្មានការអនុញ្ញាត
   - ការជជែកគ្នាខ្លាំងៗ ឬស្រែកឡូឡា ឬបង្កសំឡេងរំខានផ្សេងៗ។

៣. ហាមក្មេងអាយុក្រោម១៨ឆ្នាំ ចូលក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការ លើកលែងតែមានការអនុញ្ញាតជាមុនពីក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ។

៤. ហាមយកអាវុធជាតិផ្ទុះ សារធាតុពុល និងវត្ថុគ្រោះថ្នាក់ផ្សេងៗចូលក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការ។

៥. ហាមថតរូប និងថតសំឡេង លើកលែងតែមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ។

៦. ហាមប្រើប្រាស់ទូរសព្ទដៃ វិទ្យុទាក់ទង សម្ភារ បរិក្ខារអេឡិចត្រូនិចដែលអាចថតរូប វីដេអូ និងសំឡេងផ្សេងៗក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការ។

៧. ក្នុងករណីជនណាម្នាក់ ឬច្រើននាក់ បង្កសកម្មភាពណាមួយដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ យល់ឃើញថា ធ្វើឱ្យមានការប៉ះពាល់ដល់របៀបរៀបរយការប្រជុំផ្សះផ្សា ឬសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ អាចបណ្ដេញជននោះ ឬទាំងនោះ ចេញពីបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការ។

ជនណាមិនគោរពបទបញ្ជានេះ ឬបង្កភាពរឹករវក្នុងពេលប្រជុំផ្សះផ្សា ឬសវនាការ ត្រូវទទួលទោសតាមច្បាប់ជាធរមាន។

# ឧបសម្ព័ន្ធទី ៤
# នីតិវិធី និងខ្លឹមសារនៃសម្បថ

ការធ្វើសច្ចាប្រណិធាន ត្រូវដឹកនាំធ្វើឡើងដោយលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ ហើយត្រូវធ្វើនៅចំពោះមុខវត្ថុស័ក្តិសិទ្ធិនៅទីកន្លែងបើកសវនាការនីមួយៗ។

មុននឹងចាប់ផ្តើមធ្វើសម្បថ អ្នកស្បថត្រូវអុជទៀនធូបបូជានៅចំពោះមុខវត្ថុស័ក្តិសិទ្ធិដែលខ្លួនត្រូវស្បថនោះ។ បន្ទាប់មកលេខាធិការសវនាការ ឬសមាជិកគណៈលេខាធិការសវនាការត្រូវអានប្រារព្ធវាទខ្លាំងៗ ច្បាស់ៗឱ្យអ្នកស្បថស្តាប់ រួចអានពាក្យសច្ចាប្រណិធានឱ្យអ្នកស្បថថាតាម។

ក្រោយពីធ្វើសម្បថរួច លេខាធិការសវនាការ ឬគណៈលេខាធិការសវនាការត្រូវធ្វើកំណត់ហេតុនៃការធ្វើសម្បថនោះ ដោយបញ្ជាក់ថា បានធ្វើត្រឹមត្រូវ ហើយសេចក្តីបានចេញវាចាឱ្យស្បថយ៉ាងណាត្រូវកត់ក្នុងកំណត់ហេតុយ៉ាងនោះផង។

## ប្រារព្ធវាទ

បពិត្រអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា និងបារមីដ៏ស័ក្តិសិទ្ធិ មានព្រះអង្គដងកើ ព្រះអង្គក្រពុំឈូក ព្រះអង្គស្វេតច្ឆត្រ ព្រះអង្គចេក ព្រះអង្គចម អ្នកតាឃ្លាំងមឿង អ្នកតាក្រហមក លោកតាដំបងដែក លោកតាដំបងគ្រញូង លោកយាយទេព ព្រះអង្គវិហារសួគ៌ ព្រះអង្គព្រះជីវរ័ត្តបារាយណ៍ ព្រះអង្គវត្តភ្នំខ្លែងជាដើម សូមយាងអញ្ជើញមកធ្វើជាអធិបតីក្នុងពិធីសម្បថនេះ ដ្បិតគូភាគីនេះបានឈ្លោះទាស់ទែងគ្នា ហើយអះអាងលើសាក្សីថា ជាអ្នកបានដឹង បានឃើញ បានឮ និងបានចាំដោយផ្ទាល់ ហើយច្បាប់តម្រូវឱ្យអ្នកទាំងនេះមកធ្វើជាសាក្សីឱ្យឆ្លើយឱ្យបានទៀងត្រង់តាមការណ៍ពិត។

បើអ្នកណាឆ្លើយមិនពិតតាមដែលខ្លួនបានដឹង បានឃើញ បានឮ និងបានចាំទេ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏ស័ក្តិសិទ្ធិ បំផ្លាញឱ្យលាញ ឱ្យស្លាប់តែហោងយ៉ាងវេទនា ដោយគ្រាប់កាំភ្លើង រន្ទះបាញ់ ខ្លាខាំ ពស់ចឹក លុះអនាគតជាតិឱ្យព្រាត់ប្រាសឪពុកម្តាយបងប្អូន កូនចៅ ឱ្យក្ររហេមរហាម ខ្សត់ទ្រព្យ រងទុក្ខវេទនាអស់ប្រាំរយជាតិ។

បើអ្នកណាឆ្លើយឱ្យការណ៍ដោយពិតត្រង់ មិនវៀចវេរ មិនភូតកុហក មិនលម្អៀង ព្រោះជាញាតិសាលោហិតមិនសមគំនិតព្រោះខ្លាច ព្រោះស្អប់ ព្រោះលាភសក្ការៈ ព្រោះស៊ីសំណូកទេ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏ស័ក្តិសិទ្ធិក្នុងលោកជួយឱ្យគេមានអាយុយឺនយូរមានសុខភាពល្អ មានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ មានញាតិផៅគោរពស្រឡាញ់រាប់អានលុះអនាគតជាតិបានជួបតែសេចក្តីល្អ ចម្រុងចម្រើន ថ្កុំថ្កើន រុងរឿងសមដូចសេចក្តីបំណងប្រាថ្នាកុំបីអាក់ខានឡើយ។

## ពាក្យសច្ចាប្រណិធាន

ខ្ញុំសូមឆ្លើយតែការពិតដែលខ្ញុំបានឃើញ បានឮ បានដឹង និងបានចាំផ្ទាល់។ បើខ្ញុំឆ្លើយមិនពិតដោយប្រការណាមួយ សូមអស់ទេព្រក្ស អារក្ស អ្នកតា និងបារមីដ៏ស័ក្តិសិទ្ធិ ទាំងអស់បរាមុខខ្ញុំឱ្យវិនាសលាញ អន្តរាយទ្រព្យសម្បត្តិ និងស្លាប់តែហោងយ៉ាងវេទនា តែបើខ្ញុំឆ្លើយពិតត្រង់ សូមទេវតាជួយឱ្យខ្ញុំមានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ និងរស់នៅប្រកបដោយសេចក្តីសុខក្សេមក្សាន្តជួបជុំបងប្អូនកូនចៅ ញាតិផៅសន្តានជារៀងរហូតគ្រប់ជាតិកុំបីអាក់ខានឡើយ។

# គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## បោះពុម្ព និងផ្សព្វផ្សាយដោយ
## គ.ជ.ប

## ឆ្នាំ ២០២៤

អាសយដ្ឋាន : វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរសព្ទ : ០២៣ ២៣៥ ២៧១
Address : St., Ratsaphea Tonle Basac, Khan Chamkar Mon, Phnom Penh, Cambodia អ៊ីម៉ែល : info@nec.gov.kh